ក្រសួងអប់រំ យុវជន និង កីឡា

# ៩ ការពិភាក្សា

# បញ្ឈប់ពលកម្មកុមារ

## ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៧

## វត្ថុបំណង

ធ្វើការសិក្សា និងរៀបចំធ្វើការពិភាក្សាជាសាធារណៈមួយ ចំពោះការងារដែលជាប់ពាក់ព័ន្ធទៅនឹងពលកម្មកុមារ ។





## លទ្ធផលរំពឹងទុក

ធ្វើការអភិវឌ្ឍន៍ទៅលើការឃោសនាជាសាធារណៈ ការធ្វើការពិភាក្សានិងជំនាញផ្នែកទំនាក់ទំនង ព្រមទាំងផ្តល់ឱកាសដើម្បីស្ថាបនាចំណេះដឹងនៅតាមសហគមន៍ថែមទៀត ។



## ការកំណត់ពេលវេលា

បង្រៀន ៣ពេលដាច់ពីគ្នា ឬ ២ពេលជាប់គ្នា ប្រសិនបើមានការបញ្ចូលសកម្មភាពបង្រៀនណាមួយទៀត ។

## ហេតុផល

ការពិភាក្សា គឺជាសកម្មភាពដ៏ពិសេសមួយនៅក្នុងសង្គមប្រជាធិបតេយ្យ ។ ជាង ២000 ឆ្នាំកន្លងមក នៅពេលដែលលិទ្ធិប្រជាធិបតេយ្យបានរីកចំរើនឡើងដំបូងបង្អស់នៅក្នុងទីក្រុង Athens នៃប្រទេស Greek ប្រជាជនបានជួបប្រជុំគ្នាជាសាធារណៈយ៉ាងទៀងទាត់ ។ ហើយការបោះឆ្នោតរបស់ប្រជាជនពិតជាមានប្រសិទ្ធភាពអាចកំណត់បាននូវគោលនយោបាយ និងសកម្មភាពផ្សេងៗទៀត នៅក្នុងរដ្ឋរបស់ពួកគេ ។ ពួកគេទាំងអស់ អាចធ្វើការសម្រេចចិត្តបានថា តើទីក្រុង Athens អាចមានសង្គ្រាម រឺក៏អត់ និងថាតើវាអាចកើតមានការច្បាំងគ្នាតាមរបៀបណា ។

### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

ប្រការដែលសមហេតុសមផលគួរណែនាំ បង្ហាញអំពីម៉ូឌុលនេះ នៅពេលដែលសកម្មភាពមានដំណើរការបានពាក់កណ្តាល ។ ដើម្បីធ្វើលំហាត់បែបនេះឱ្យដំណើរការល្អ ជនវ័យក្មេងគួរតែមានចំណេះដឹងពីមុនល្អៗដែលពាក់ព័ន្ធទៅនឹងបញ្ហាពលកម្មកុមារ ហើយគួរតែដឹង ឱ្យប្រាកដថែមទៀត អំពីរបៀបធ្វើការស្រាវជ្រាវ របស់ខ្លួនឯងផ្ទាល់ ។ លំហាត់នេះតម្រូវ ឱ្យពួកគេមានមតិ "គាំទ្រ" ឬ "ប្រឆាំង" ចំពោះប្រធានបទណាមួយដោយរៀបចំឱ្យមានអំណះអំណាងសមហេតុសមផលនិងត្រឹមត្រូវជាក់ស្តែង ។ ដូចនេះយើងសូមផ្តល់ជាអនុសាសន៍ថាម៉ូឌុលនេះមិនគួរយកមកបង្ហាញ នៅមុនពេលបង្ហាញម៉ូឌុលអំពីការស្រាវជ្រាវ និងព័ត៌មានឡើយ ។ ប្រការល្អប្រហែលជាត្រូវរង់ចាំ រហូតដល់ម៉ូឌុល "ការសរសេរនិពន្ធ" ប្រកបដោយការច្នៃប្រឌិតត្រូវបានបញ្ចប់ ។

ព្រមទាំងមានការបង្កើតច្បាប់សម្រាប់ អប់រំ និងដឹកនាំ គ្រួសារទៀតផង ។

ប៉ុន្តែការបោះឆ្នោតរបស់ពួកគេតែងតែប្រព្រឹត្តទៅដោយយកការពិភាក្សាជាធំដែរ ។ ប្រជាជន និងអ្នកដឹកនាំជជែកតវ៉ាគ្នាជាមុន ថាតើអ្វីទៅជាច្បាប់ និងសិទ្ធិធ្វើអ្វីខ្លះដែលស្របច្បាប់ និងសិទ្ធិអ្វីខ្លះដែលមិនស្របច្បាប់ ។



### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

ទូទាំងពិភពលោកនេះ ការពិភាក្សាជាសាធារណៈមានប្រពៃណី ឬទម្លាប់ខុសៗគ្នា ។ របៀបមួយដែលគេស្គាល់ ដ៏ទូលំទូលាយបំផុតនោះ គឺការពិភាក្សាគ្នា ដោយផ្អែកទៅលើគំរូជាសភា ក្នុងនោះក្រុម ឬបុគ្គលត្រូវពិភាក្សា អំពីប្រធានបទមួយដែលគេបង្ហាញជាដំណោះស្រាយ ឬជាប្រធានបទសម្រាប់ពិភាក្សា ។ គេរំពឹងទុកថាក្រុមមួយ ឬបុគ្គលម្នាក់ត្រូវគាំទ្រដល់ដំណោះស្រាយ ដោយបង្ហាញនូវអំណះអំណាង ក្នុងការគាំទ្ររបស់ខ្លួន ហើយជំទាស់ចំពោះករណីដែលក្រុម ឬបុគ្គលប្រឆាំងម្នាក់ទៀតបានលើកឡើងផ្ទុយនឹងដំណោះស្រាយនោះ ។

គេរំពឹងថា ក្រុមប្រឆាំង ឬបុគ្គលប្រឆាំងអាច ពោលជំទាស់នឹងដំណោះស្រាយនោះ

គេអាចអនុវត្តម៉ូឌូលនេះនៅមុនពេល ឬអាចក្រោយពេលអនុវត្តម៉ូឌុលទាំងឡាយ ដែលពាក់ព័ន្ធនឹងការសម្តែងសិល្បៈទៅតាមវិធីណាមួយ ក៏បាន ។

បច្ចុប្បន្ននេះកិច្ចពិភាក្សានៅតែដើរតួសំខាន់នៅឡើយចំពោះប្រទេសដែលកាន់លិទ្ធិប្រជាធិបតេយ្យ ។

ក្នុងបណ្តាប្រទេសដែលមានភាពជឿនលឿន និងមានប្រជាជនរបស់ខ្លួនច្រើន និងទ្រង់ទ្រាយភូមិសាស្ត្រធំ គោលការណ៍លិទ្ធិប្រជាធិបតេយ្យ ក៏បានផ្លាស់ប្តូរច្រើនជាងទីក្រុង Athens ដែលជាទីក្រុងបុរាណខ្លាំងណាស់ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏ការពិភាក្សានៅតែបន្តរហូតដល់បច្ចុប្បន្ន ។ កិច្ចពិភាក្សាមួយចំនួនត្រូវបានយកទៅអនុវត្តក្នុងការតាក់តែងច្បាប់របស់សភា ។

ការពិភាក្សាជាជំនួយការប្រៀនប្រដៅ និងដោះស្រាយបញ្ហាជាសាធារណៈនៅតាមភូមិ ក៏ដូចជាសហគមន៍តូចៗផងដែរ ។

កិច្ចពិភាក្សា ក៏មានវត្តមាននៅតាមសាលាសកលវិទ្យាល័យ រឺត្រូវបានគេអានតាមអត្ថបទទស្សនាវដ្តី រឺកាសែត និងត្រូវបានស្តាប់ឮតាមវិទ្យុមើលឃើញតាមកញ្ចក់ទូរទស្សន៍ តាមប្រវត្តិសាស្ត្របុរាណ ដែលសរសេរអំពីអ្នកដឹកនាំ ។ ប្រជាជនជជែកវែកញែករកផ្លូវដ៏ល្អបំផុតសម្រាប់សង្គមរបស់ខ្លួនព្រមទាំងកែលំអច្បាប់តុលាការក៏

**កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់**

ហើយបដិសេធនីនូវអំណះអំណាង ដែលអ្នកដទៃធ្វើឡើងក្នុងបំណងការពារ។

ម៉ូឌុលនេះ បង្ហាញការយកចិត្តទុកដាក់ជាសំខាន់ទៅលើគំរូនេះ ប៉ុន្តែប្រការសំខាន់គឺថាក្នុងការអនុវត្តម៉ូឌុលនេះ អ្នកអប់រំនៅតាមបណ្តាប្រទេសផ្សេងៗគ្នា ទូទាំងសកលលោក ត្រូវគោរពទៅតាមប្រពៃណី និងវប្បធម៌នៃការពិភាក្សា ក្នុងសង្គមដែលខ្លួនឯងរស់នៅផ្ទាល់។

ដូចជា គោលនយោបាយ និងសកម្មភាពដឹកនាំ។ ហើយពួកគេ ក៏អាចសម្រេចបាននូវលទ្ធផលដ៏ល្អបំផុត បន្ទាប់ពីការជជែកគ្នានោះ។ ដូច្នេះពួកគេ ក៏ដឹងអំពីអ្វី ដែលអាចប្រព្រឹត្តទៅបាន និងអ្វីដែលមិនអាចប្រព្រឹត្ត និងត្រូវប្រុងប្រយ័ត្ននោះ។

ការឆ្លងកាត់បទពិសោធន៍ទាំងនេះ បានធ្វើឱ្យវិស័យជាច្រើនបានរីកចំរើនខ្លាំងឡើងៗ ដូចជាវិស័យទំនាក់ទំនងសង្គម វិស័យទាំងឡាយ ដែលត្រូវការសមត្ថភាព ឃោសនាជាសាធារណៈ កត្តិវិទ្យា ព្រមទាំងសមត្ថភាពស្ថាបនា និងការពារជំលោះថែមទៀតផង។ ក្នុងស្ថានភាពសង្គម ទាំងអស់ក្មេងៗត្រូវការឱ្យគេផ្តល់ការទទួលខុសត្រូវ ដ៏ច្រើនថែមទៀត ចំពោះការងារដែលពាក់ព័ន្ធចំពោះពួកគេ។ តម្រូវការនេះទាមទារឱ្យមានការទទួលខុសត្រូវឱ្យបានច្រើនថែមទៀត សម្រាប់ក្រុមក្មេងៗទាំងនោះ។ ការពិភាក្សាអាចផ្តល់នូវព័ត៌មានដ៏ល្អមួយ ស្តីពីពលកម្មកុមារទាំងអស់ប្រកបដោយអត្ថន័យធំធេង។

កុមារពលកម្មទាំងនោះតែងធ្វើការពិភាក្សា រៀបចំឯកសារដែលជាមូលដ្ឋានព័ត៌មាន ដែលពួកគេបានទទួលតាមរយៈការសិក្សាស្រាវជ្រាវរបស់ពួកគេ។ ដោយមានការផ្តល់ចំណេះដឹង តាមការអប់រំ ពួកគេមានការអភិវឌ្ឍន៍ផ្នែកខាងការពិភាក្សា និងការធ្វើការសន្និដ្ឋានដោយខ្លួនគេ។

ការចូលរួមក្នុងកិច្ចពិភាក្សាជួយឱ្យក្មេងៗចេះជជែកគ្នាដើម្បីដោះស្រាយការងារ ដ៏ជាក់លាក់ទាំងឡាយបាន។ ពួកក្មេងៗទាំងនោះបានទទួលស្គាល់ថា ចំណេះដឹង និងព័ត៌មាន ដែលពួកគេចេះពីមុននោះ គឺត្រូវតែយកទៅអនុវត្ត។ ដូចនេះជំនាញដែលបានរៀនចេះមកនោះ គឺពួកគេយល់ថា គ្រប់ការងារគឺមានពីរផ្នែក សូម្បីតែ ការងាររបស់កុមារ



ក៏ដោយ។ អ្វីៗទាំងអស់មិនមែនសុទ្ធតែអាក្រក់នោះទេ ហើយមិនមែនសុទ្ធតែល្អនោះដែរ។ ដោយឡែកការងារពលកម្មរបស់កុមារក៏មានច្រើនបែបច្រើនយ៉ាងដែរ។ គ្មានចំលើយងាយស្រួល ក្នុងការវ៉ាយវ៉ាប់ប្រភេទពលកម្មទាំងនោះទេ។ ពិភាក្សាដើម្បីដោះស្រាយលើប្រធានបទដែលបានលើកឡើងដំបូងនេះ គឺជាការប្រើប្រាស់សិទ្ធិប្រកបដោយសីលធម៌ល្អមួយ ហើយពិបាកអនុវត្តណាស់។ ប៉ុន្តែគួរឱ្យសោកស្តាយរឿងដែលមនុស្សធ្វើការពិភាក្សាទាំងនោះ បែរជាទទួលនូវស្ថានភាពដ៏តឹងតែង ហើយបញ្ចប់ដោយជំលោះទៅវិញ។

ដោយមានការឧបត្ថម្ភពីអ្នកអប់រំពួកគេរកបានព័ត៌មាន និងហេតុផលជាច្រើន។ ការពិភាក្សាទាំងនេះនឹងត្រូវវាយតម្លៃ ដោយខ្លួនឯង និងឈានទៅពង្រឹងការសិក្សា និងដំណើរការយល់ដឹង។ ដើម្បីធ្វើអ្វីមួយឱ្យប្រាកដ ពួកគេត្រូវស៊ីជំរៅទៅលើអត្តចរិតរបស់ពលកម្មកុមារ និយោជិក អាជ្ញាធរជាច្រើនទៀត ឬស៊ីជំរៅអ្វីដែលពួកគេពិភាក្សាលើករណីរបស់គេ ដើម្បីឱ្យជឿលើការគាំទ្រ។ ទាំងនោះគឺជាបទពិសោធន៍ដ៏រឹងមាំ ដែលផុសចេញពីគំនិតខ្លួនឯង។

ពួកគេត្រូវយល់ដឹងគោលជំហរ ឬស្ថានភាពនៃអ្វីដែលពួកគេមិនឯកភាព ឬគាំទ្រ។



## ការរៀបចំ

ទោះបីយ៉ាងណាក៏ដោយ ពិភពលោកមានប្រពៃណីខុសៗគ្នាជានិច្ចនៅតាមតំបន់។ យើងជឿថា អ្នកទាំងអស់នោះទទួលយកបែបបទពិភាក្សា ទៅតាមក្បួនខ្នាត និងប្រពៃណីរបស់គេផ្ទាល់។

អ្នកគប្បីផ្អែកទៅលើសម្ភារ និងឯកសារយោងឱ្យបានច្រើនគ្រប់គ្រាន់សម្រាប់ការពិភាក្សា។

សម្ភារទាំងនេះអាចស្វែងរកបាននៅក្នុងបណ្ណាល័យ ជាច្រើនតាមតំបន់ រឺនៅលើអ៊ិនធឺណែតប្រសិនបើអ្នកអាចមានលទ្ធភាព។

ម្យ៉ាងទៀតអ្នកអាចទៅទំនាក់ទំនងជាមួយអង្គការនានាតាមតំបន់ ជាពិសេសមុខរបរជំនួញ ដែលវាអាចជួយអ្នកនៅការអនុវត្តន៍ប្រធានបទទាំងនេះ (មើលការគាំទ្រពីក្រៅ)។

ទោះបីគេបានពាក្យ “Topic” ជាប្រធានបទរួចហើយក៏ដោយ សូមឱ្យមានភាពទន់ភ្លន់នៅក្នុងការបកស្រាយរបស់ពាក្យទាំងនោះ។ ឧទាហរណ៍ផ្ទុយពីការប្រើប្រាស់នៃពាក្យចំណងជើងប្រធានបទ "Concept" ដោយប្រើប្រាស់ពាក្យឥរិយាបថ "position" រឺជំនឿ "Belief"។ នៅក្នុងសហគមន៍មួយ វាហាក់ដូចជាការពិភាក្សាជាសាធារណៈនៅតែជាមធ្យោបាយមួយល្អនៃជីវិត ហើយការពិភាក្សាជាប្រពៃណីមួយខ្លាំង ដែលអាចមាននៅក្នុងក្រុមអ្នកទាំងនោះ។

យោបល់ឆ្លាស់គ្នាតែរាល់ការពិភាក្សាទាំងអស់ត្រូវបានបញ្ចូលនៅក្នុងអត្ថបទដោយរក្សាទុកទិដ្ឋភាពខុសៗគ្នា ហើយវាមានការបត់បែនយ៉ាងខ្លាំង និងទស្សនៈគួរទទួលយកបាន អ្នកអប់រំគួរតែមិនមានអារម្មណ៍ភ័យខ្លាចក្រែងធ្លាក់ចូលក្នុងផ្លូវដែលគេហាមឃាត់ដែលគេហៅថាច្បាប់វិន័យ តើដំណើរការអ្វីដែលធ្វើឱ្យប្រសើរជាងនេះទៀត។ គឺវាមិនត្រូវបានបញ្ចប់ក្នុងន័យដើមរបស់វាឡើយ។

*ជំនួយពីខាងក្រៅ*

ម៉ូឌុលពិភាក្សាមានន័យចំៗមិនលំអៀងពីទស្សនៈ (Concept) ហើយមិនបង្កឱ្យការលំបាកដល់ការអនុវត្តន៍ឡើយ។
ទោះបីយ៉ាងណាក៏ដោយប្រសិនបើអ្នកនៅក្នុងបរិស្ថានសាលា អ្នកប្រហែលជាមានសង្គមពិភាក្សាជាក្រុមពិភាក្សា ដែលគ្រូបង្រៀនអ្នកសម្របសម្រួលនៃក្រុមនោះមានការចាប់អារម្មណ៍ក្នុងការចូលរួមក្នុងការហ្វឹកហ្វឺននេះ។ ការទំនាក់ទំនង ជាមួយគាត់ រឺជាមួយនាងអាចពង្រឹងដំណើរបញ្ជ្រាបសហគមន៍។ ទោះយ៉ាងនេះក៏ដោយការសំខាន់គឺការផ្តោតទៅលើក្មេងៗនៅក្រុមផ្ទាល់របស់អ្នក ហើយត្រូវដឹង

ឱ្យប្រាកដថា ពួកគេទាំងអស់ត្រូវបានធ្វើឱ្យមានទំនាក់ទំនង ។

*ជំនួយពីក្រៅ*

លើសពីនេះទៅទៀត ត្រូវចាំទុកថាអង្គការមួយចំនួនពិសេសសមាគមពាណិជ្ជកម្ម មានប្រវត្តិពិភាក្សាយ៉ាងវែងដូចជាវិធីសាស្ត្រ ដែលត្រូវឈានទៅដល់ការសម្រេចចិត្ត តាមបែបប្រជាធិបតេយ្យ ។

ម៉ូឌុលពិភាក្សានេះនឹងត្រូវបានពិភាក្សានៅក្នុងកំឡុងពេលសន្និសីទ និងការប្រជុំនានា ។

បន្ទាប់មកការសម្រេចចិត្តនឹងត្រូវបានគេប្រកាន់យកជាមូលដ្ឋាន ដោយទុកដូចជាការបញ្ចូលសហគមន៍ក្រុមពិភាក្សា ត្រូវយកចិត្តទុកដាក់ធ្វើទំនាក់ទំនង ជាមួយការិយាល័យពាណិជ្ជកម្ម នៅតាមតំបន់ ដើម្បីមើលឃើញថា តើការិយាល័យ មានឆន្ទៈមកធ្វើការជាមួយក្រុមស្ដីពីបច្ចេកទេសពិភាក្សា និងរៀបចំការពិភាក្សា ជាសាធារណៈ ។

អង្គការពាណិជ្ជកម្មជាច្រើនមានសម្ភារអប់រំ សម្រាប់ការពិភាក្សាមួយ ដែលពួកគេអាចយកទៅប្រើជាប្រយោជន៍បាន ។



អ្វីដែលអ្នកត្រូវការ

- ✓ ក្រដាស ប៊ិចរី ខ្មៅដៃ
- ✓ សម្ភារស្រាវជ្រាវ អំពីកុមារពលកម្ម (IPEC) និងធនធានដទៃទៀត
- ✓ ប្រើអ៊ីនធឺណែត ប្រសិនបើអាច
- ✓ មានបន្ទប់មួយដើម្បីធ្វើការពិភាក្សា និងសម្រួលអ្នកស្តាប់ទាំងឡាយ ប្រសិនបើការពិភាក្សាមានអ្នកស្តាប់ ចំនួនច្រើន។
- ✓ មីក្រូហ្វូន រឺរបស់របរផ្សេងៗទៀតដែលត្រូវយកមកប្រើប្រាស់ ដូចជាប្រដាប់បំពងសំលេង (magic mike) ក្នុងការផ្លាស់ប្តូរ សកម្មភាពពិភាក្សា។





## ការចាប់ផ្តើម

*១-បង្រៀនមួយពេល*

ជំហានទី១នៃដំណើរការការងារ គឺត្រូវបង្កើតនូវការយល់ដឹងគោលសម្រាប់ក្រុម ឬសម្រាប់អ្វីដែលគេហៅថាពិភាក្សា ហើយហេតុអ្វីបានជាមានប្រយោជន៍ក្នុង ដំណើរនៃការអប់រំ។

ការប្រជុំលើកទី១នេះ ត្រូវធ្វើជាមួយក្រុមទាំងមូល។ សមាជិកទាំងអស់ត្រូវអង្គុយជារាងដូចក្រចកជើងសេះជុំវិញអ្នក។ ពួកគេមិនត្រូវធ្វើការកត់ត្រាក្នុង ដំណាក់កាលនេះទេ។

ប្រសិនបើអ្នកធ្វើសកម្មភាពទីមួយ អ្នកត្រូវអនុវត្តការផ្លាស់ប្តូរពិភាក្សាជាមួយក្រុម របស់អ្នកបន្ទាប់មកអ្នកអាចណែនាំក្រុមឱ្យធ្វើសកម្មភាពដោយផ្ទាល់តែម្តង។ ទោះបីបែបនេះក៏ដោយ ប្រសិនបើអ្នកបំរុងធ្វើការណែនាំជាក្រុម ឱ្យពិភាក្សាសកម្មភាពជាផ្លូវការ អ្នកគប្បីចំណាយពេលវេលាខ្លះទៅលើការពិភាក្សា ដើម្បីដឹងថា តើដំណើរការពិភាក្សាគប្បី

ប្រព្រឹត្តទៅដោយរបៀបណា? ។

សូមមើលឧបសម្ព័ន្ធទី១ តាមតែអ្នកអាចយល់ឃើញថា មានប្រយោជន៍ប៉ុនណានោះ។ តាមបែបផ្សេងត្រូវផ្ដោតទៅលើវប្បធម៌ និងប្រពៃណីតាមតំបន់ដែលមានឥទ្ធិពលមកលើការពិភាក្សាជាការល្អប្រសើរ ត្រូវពន្យល់អំពីគោលបំណង និងទិសដៅនៃការពិភាក្សាប្រធានបទនេះ ត្រូវបានគេបង្កើតឡើង ហើយបន្ទាប់មកបុគ្គល ២នាក់ បង្ហាញអំណះអំណាងគាំទ្រ និងប្រឆាំងប្រធានបទមុននឹងដាក់ជូនគណៈកម្មការវិនិច្ឆ័យ។ បើនិយាយយ៉ាងសមញ្ញស្រួលយល់តាមការបង្ហាញអំណះអំណាងដំបូងក្រុមនីមួយៗត្រូវបានអនុញ្ញាតឱ្យឆ្លើយតបទៅនឹងអំណះអំណាងលើកឡើង ដោយក្រុមប្រឆាំងហើយបដិសេធអំណះអំណាងនោះ ក្នុងក្ដីសង្ឃឹមថានឹងឈ្នះ អង្គសាវនាការ និងទទួលបានពិន្ទុពីគណៈកម្មការវិនិច្ឆ័យ។

អាស្រ័យដោយអ្នកអប់រំ និអង្គប្រជុំគប្បីទទួលសំណួរពីអ្នកស្ដាប់ ឬអនុសាសន៍ ដែលគាំទ្រក្រុមណាមួយ។ ត្រូវប្រាប់ក្រុមទាំងនោះថា អ្នកទាំងឡាយណាដែលចូលរួមការហ្វឹកហ្វឺននឹងត្រូវផ្ដល់ នូវពេលវេលាមួយគ្រប់គ្រាន់រហូតដល់ការប្រជុំលើកក្រោយ ដើម្បីរៀបចំការវាយតម្លៃ យុទ្ធសាស្ត្រ និងជ្រើសរើសប្រធានក្រុមប្រសិនបើចាំបាច់។

ចំណុចនៃកាហ្វឹកហ្វឺននេះ គឺមិនមែនយកឈ្នះ លើពួកពិភាក្សានោះទេ ក៏ប៉ុន្តែវាជាការចូលរួម ក្នុងការស្រាវជ្រាវ និងការរៀបចំអំណះអំណាងដើម្បី គាំទ្រ ឬប្រឆាំងប្រធានបទ។ នៅក្នុងមធ្យោបាយនេះប្រធានបទអាចជាបញ្ហាពាក់ព័ន្ធទៅនឹងកុមារពលកម្មក្រុមទាំងនេះ ត្រូវសិក្សាស្រាវជ្រាវរាល់ព័ត៌មានស្ដីអំពីជីវប្រវត្តិ។ ត្រូវបញ្ជាក់ប្រាប់ដល់ពួកវា ពួកគេនឹងត្រូវគាំទ្រ ក្នុងការរៀបចំអំណះអំណាង ហើយរបាយការណ៍ មិនត្រូវបានសន្មតថាវែង រឺ ដកចេញឡើយ។ គន្លឹះជាយុទ្ធសាស្ត្រ គឺសេចក្ដីថ្លែងត្រូវតែឧទាហរណ៍ ត្រូវតែច្បាស់ ដើម្បីគាំទ្រអំណះអំណាង។

ជាការពិតរឿងដែលសំខាន់ គឺត្រូវពន្យល់ប្រាប់ដល់ក្រុមថា ត្រូវឱ្យមានការតិតៀនរិះគន់ ដើម្បីកែតម្រូវ ហើយការបង្ហាត់បង្រៀនខ្លះ គួរតែ

ផ្តល់នូវបច្ចេកទេសបរិយាយជាសាធារណៈ ។ ម្យ៉ាងទៀតប្រសិនបើអ្នក បានទទួលការគាំទ្រពីខាងក្រៅ ដើម្បីឱ្យជួយបង្ហាត់បង្រៀននូវការប្រើប្រាស់សូមប្រើវាចុះ ។ កាលណាក្រុមពិភាក្សាត្រូវបានគេជ្រើសរើសរួចហើយ ត្រៀមចាប់ផ្តើមធ្វើការបង្ហាញនូវរបាយការណ៍ទាំងនោះ ពួកគេតម្រូវការបរិយាកាសស្ងប់ស្ងាត់ ដើម្បីពិភាក្សាអំពីយុទ្ធសាស្ត្រនៃការអនុវត្តន៍ការស្រាវជ្រាវ និងរៀបចំនូវរបៀបនិយាយ ។

នេះគឺជារយៈពេលមួយដែលពួកគេត្រូវការគាំទ្រ ពីសំណាក់អ្នកអប់រំឱ្យបានច្រើន ។ ការប្រជុំឱ្យកាន់តែប្រសើរបំផុត គឺការប្រជុំក្នុងថ្នាក់ ។

ឧទាហរណ៍ : កុមារដែលកំពុងសរសេរនៅចំពោះមុខគាត់ ហើយសរសេរពីឧបករណ៍ប្រើប្រាស់ ។

ចំពោះការពិភាក្សាផ្លាស់ប្តូរ វាជាការប្រសើរសម្រាប់ក្រុមកុមារទាំងមូលព្រោះអ្នកត្រូវការ ធ្វើការលើកទឹកចិត្តដល់ក្មេងៗ ឱ្យពួកគេនិយាយសំដែងយោបល់សម្រាប់ក្រុមទាំងមូលនៅចំពោះមុខសមភាគីរបស់ពួកគេ ។ នេះជាសិទ្ធិយ៉ាងសំខាន់របស់មនុស្សគ្រប់រូបក្នុងនោះមានកុមារ និងក្មេងៗ ដែលអាចនិយាយសំដែង យោបល់ដោយសេរីភាព ម្យ៉ាងទៀតវាជាគោលបំណងយ៉ាងសំខាន់ដែលមនុស្ស ម្នាក់ធ្វើការពិភាក្សាផ្លាស់ប្តូរដូច្នេះ ។



ការពិភាក្សាជាផ្លូវការ អាចជាការហ្វឹកហ្វឺនជាក្រុម រឺហ្វឹកហ្វឺនម្តងមួយក្រុមៗ ។ ទំហំនៃការពិភាក្សាអាស្រ័យទៅលើទំហំនៃក្រុមរបស់អ្នក តាមការពិត គោលគំនិតគឺត្រូវលើកទឹកចិត្តយុវជនទាំងនោះឱ្យនិយាយ សំដែងយោបល់ និងឱ្យមានការលូតលាស់ ជាលទ្ធផលស្តែងចេញពីវិធី ឬដំណើរការទាំងអស់នោះ ។

ប្រសិនបើក្រុមធំ អ្នកអាចបង្កើតនូវក្រុមពិភាក្សាមានគ្នា ពី ២ ទៅ ៣ នាក់ ដែលត្រូវមានចរិតទន់ភ្លន់ មិនត្រូវមានចំនួនច្រើនជាងនេះទេ ។ ត្រូវចងចាំថា សមាជិកនីមួយៗរបស់ក្រុម ត្រូវធ្វើការពិភាក្សាលើចំណុចដដែល ដោយរក្សាក្រុមឱ្យនៅតូចៗអ្នកចៀសផុតពីការដដែលៗ ។

ប្រសិនបើអ្នកមានក្រុមធំជាការប្រសើរត្រូវបង្កើតប្រធានបទ ២ ឬ៣

សម្រាប់ពិភាក្សា ហើយជ្រើសរើសក្រុមសម្រាប់ជជែកប្រឆាំង និងក្រុមសម្រាប គាំទ្រ។

បើអ្នកដាក់វិធានការណ៍តឹងរឹងក្នុងការពិភាក្សាអ្នកត្រូវតែងតាំងគណៈ វិនិច្ឆ័យ (មើលឧបសម្ព័ន្ធទី១) តើនរណាសម្រេចលទ្ធផលនៃការពិភាក្សាលើមូល ដ្ឋាននៃការបង្ហាញមតិយោបល់ និងការពិភាក្សា។

វាជាការប្រសើរត្រូវមានចំនួនសេសនៅក្នុងគណៈវិនិច្ឆ័យ ដូច្នេះចំនួន៣ គឺជាការជ្រើសរើសបានល្អ។ អ្នកវិនិច្ឆ័យគប្បីត្រូវបានទាញចូលទៅក្នុងក្រុម ដើម្បី ឱ្យគេចូលរួមក្នុងដំណើរការវិនិច្ឆ័យ។ ទោះយ៉ាងណាក៏ដោយអ្នកគប្បី យកចិត្ត ទុកដាក់អញ្ជើញអ្នកផ្សេងទៀតមក ចូលរួមធ្វើសកម្មភាពដូចជាអ្នកវិនិច្ឆ័យ។ អ្នក ទាំងនោះអាចមកពីសាលាណាមួយ។ ត្រូវគិតដោយប្រុងប្រយ័ត្នដល់ក្រុមដែល ស្វាហាប់ នៅពេលជ្រើសរើសក្រុមពិភាក្សា និងក្រុមអ្នកកាត់សេចក្តី។

សូមព្យាយាម និងរកឱ្យបាននូវចំណងទាក់ទងដូចជាការបញ្ចូលគ្នានៃ ភេទប្រុសស្រី ជាដើម។ ប្រសិនបើអ្នកមានសម្បជញ្ញៈចំពោះអ្នកចូលរួមក្នុងក្រុម ដែលបានសំដែងក្នុងការហ្វឹកហ្វឺននេះ សូមអ្នកព្យាយាមបែងចែកពួកគេ ជាក្រុម ក្នុងចំណោមផ្សេងៗគ្នា។ ម្យ៉ាងទៀតជាការល្អត្រូវជួយពួកគេ ឬក្រុមគេឱ្យបាន ច្រើនប្រសិនបើពួកគេស្ថិតនៅក្នុងក្រុម ដែលមានការលំបាកសម្រាប់ជជែក ដើម្បី គាំទ្រ។

*សវនការ*

ការពិភាក្សា គឺជាការជំរុញយ៉ាងខ្លាំងក្លា ជាការឱ្យរង្វាន់ និងជាការ សប្បាយដើរលេង ប្រសិនបើមានការរៀបចំសវនការ។ ក្រុមរបស់ត្រូវធំល្មម អាចធ្វើសកម្មភាពប្រៀបបាននឹងសវនការ។ ប្រសិនបើអ្នកធ្វើការក្នុងកន្លែងអប់រំ ផ្លូវការ ឬនៅកន្លែងណា ដែលអ្នកអាចចូល ធ្វើការជាមួយក្រុមយុវជនបាន សូម អ្នកអញ្ជើញក្រុមណាមួយឱ្យមកស្តាប់ការពិភាក្សា។ រឿងមានសារៈសំខាន់ ដោយ ផ្អែកលើមូលហេតុ ៣យ៉ាង :

- វាបង្កើនកំលាំងរឹងមាំទៅលើក្រុមពិភាក្សា ហើយកំលាំងនេះ និង ជួយសម្រួលសកម្មភាពពិភាក្សា។ ពួកគេត្រូវតែនិយាយជា សាធារណៈចំពោះអ្នកស្តាប់ និងចំពោះអ្នកដែលជាដៃគូរបស់គេ ដែលនឹងពង្រឹងការសំដែងរបស់គេឱ្យបានល្អ។

- វានឹងបង្កើនការយល់ដឹង និងប្រសិទ្ធភាពនៃដំណើរការលើកកំពស់សម្បជញ្ញៈ។ អង្គសវនាការនឹងស្តាប់ការពិភាក្សាអំពីរឿងពាក់ព័ន្ធ ទៅនឹងកុមារពលកម្មនឹងមាន ការយល់ដឹងថា វិធីនេះនឹងផ្តល់សារៈសំខាន់ដល់កុមារដទៃទៀត។ វានឹងធ្វើឱ្យកាន់តែកើនឡើងនូវតម្លៃ និងឥទ្ធិពលអ្វីដែលពួកគេកំពុងស្តាប់។
- វានឹងបង្កើនឱ្យកាន់តែខ្លាំងនូវសេចក្តីទុកចិត្តលើខ្លួនឯង និងតម្លៃខ្លួនឯងរបស់យុវជន ដែលបានចូលរួមចំណែកក្នុងការពិភាក្សា។ ពួកគេនឹងយល់ថា ពួកគេបានរួមចំណែកក្នុងបទពិសោធន៍សំខាន់ៗ និងឈានទៅដល់ចំណេះដឹង ដែលពួកគេទើបតែនឹងទទួលបានថ្មីៗដោយខ្លួនឯង។

ជាងនេះទៅទៀត អ្នកអាចអនុញ្ញាតឱ្យអ្នកស្តាប់ការពិភាក្សា ធ្វើជាអ្នកវិនិច្ឆ័យម្យ៉ាងទៀតនៅពេលដែលអ្នកនិយាយឈប់និយាយភ្លាម ហើយអំណះអំណាង ត្រូវបានលើកឡើង រួចហើយត្រូវបង្វែរ សេចក្តីសម្រេចចិត្តទៅអ្នកស្តាប់ធ្វើបន្ថែម ចំពោះអ្នកដោយឆ្លងកាត់វិធីបោះឆ្នោត ឬបង្វែរទៅឱ្យក្រុមដែលជជែកគាំទ្រថា ករណីរបស់គេ គឺល្អប្រសើរ។

នេះជាដំណើរការប្រជាធិបតេយ្យដ៏ល្អ ហើយអ្នកអាចសួរទៅមនុស្ស ១ ឬ ២នាក់ ដោយព្រាវៗនៅក្នុង ចំណោមអ្នកអ្នកស្តាប់ដោយពន្យល់ថា ហេតុអ្វីបានជាពួកគេអនុម័តយកមធ្យោបាយមួយនេះ ឬមួយផ្សេងទៀត។

ដោយពឹងផ្អែកទៅលើគោលបំនង និងទិសដៅរបស់ក្រុម អ្នកត្រូវយកចិត្តទុកដាក់ធ្វើការអញ្ជើញឱ្យបានទូលំទូលាយ ដើម្បីចូលរួមការពិភាក្សា ក្នុងនោះអញ្ជើញឳពុកម្តាយ អាជ្ញាធរ គ្រូ បង្រៀន អង្គការផ្សព្វផ្សាយ និង ដៃគូក្នុងសង្គម ។ល។

## សកម្មភាព ១ ៖ ចលនាពិភាក្សា

*បង្រៀនពីរពេលជាប់គ្នា*

*ដំណើរការតាមបច្ចេកទេស ៖* គឺជាវិធីសាស្ត្រមួយដែលមានប្រសិទ្ធភាពក្នុងការគ្រប់គ្រង ការពិភាក្សាដែលមិនមានការភ័យខ្លាច ហើយសប្បាយរីករាយ មានសេចក្តីទុកចិត្តនៅក្នុងក្រុម ។

ការពិភាក្សារបៀបនេះត្រូវបានព្ទ ដោយអង្គការនានានៅលើពិភពលោក មានអ្នកចរចារ និងផ្សះផ្សារដើម្បីសន្តិភាព ។ ការពិភាក្សានេះជំរុញក្រុមមកពីគ្រប់ផ្នែកឱ្យរកឃើញនូវមូលដ្ឋានរួម រួចចាប់ផ្តើមធ្វើការសន្ទនា ។

ការហ្វឹកហ្វឺន ជួយយុវជន ឱ្យយល់ថា យ៉ាងហោចណាស់អាចមានពីរផ្នែកដែលជួបប្រទះបញ្ហាច្រើន ហើយគ្មានផ្នែកណាមួយទទួលខុស ឬត្រូវឡើយ ។

ជាលំហាត់បង្កើតឱ្យមានការជឿជាក់ទុកចិត្ត ការគោរព ការយល់ដឹងនៅក្នុងការពិភាក្សា ទាល់តែបុគ្គលនីមួយៗអាចសំដែងចេញ មកនូវមតិយោបល់ដោយគ្មានការភិតភ័យ ។

លំហាត់ពិភាក្សានេះជួយយុវជនឱ្យយល់ថា ប្រសិនបើពួកគេមានគំនិត ឬមតិស្តីពីបញ្ហាណាមួយ ទោះបញ្ហានោះជាអ្វី ក៏ដោយក៏ពួកគេមានគោលជំហរប្រឆាំងនឹងគំនិតនៃអ្នកភាគច្រើន ។ ពួកគេត្រូវមានសេចក្តីក្លាហានរក្សាជំនឿរបស់ពួកគេដោយគ្មានការភ័យខ្លាច ។ លើសពីនេះទៅទៀត ការពិភាក្សាជួយយុវជនឱ្យ យល់ដឹងគោលការណ៍គោរពគ្នាទៅវិញទៅមក គោលការណ៍ សេរីភាពដូចជា សេរីភាពក្នុងការនិយាយបញ្ចេញមតិជាដើម ។ ដំណើរការពិភាក្សាផ្តល់ឱ្យយុវជននូវច្រកមួយសម្រាប់ដោះខ្លួននៅពេលដែល ពួកគេមានអារម្មណ៍ត្រូវហាមឃាត់ ខ្វះការទុកចិត្តខ្លួនឯង យល់មិនបានច្បាស់ល្អ នូវបញ្ហាដែលត្រូវធ្វើសម្រេចចិត្ត ទោះបីពួកប្រឆាំង ឬគាំទ្រក៏ដោយ ។

ក្នុងលំហាត់នេះយុវជនអាចចង្អុលបង្ហាញឱ្យឃើញថា ពួកគេមិនស្គាល់ ឬមិនទាន់សម្រេចចិត្តនៅឡើយ ។ ផ្នែកដែលមានឥទ្ធិពលខ្លាំងនៃដំណើរការពិភាក្សាគឺថា បើមានអ្នកណាមួយដែលអាចប្តូរចិត្តគំនិតនៅពេលណាមួយ ព្រោះថា ពួកគេស្តាប់ព្ទឧត្តមគតិ និងស្គាល់តិរិយាបថស្ទែងឡើងដោយអ្នកផ្សេងទៀត ។

រឿងនេះគឺជាការអភិវឌ្ឍដ៏សំខាន់សម្រាប់យុវជន បានសេចក្តីថា ពួកគេអាចយល់ដឹងថា ខ្លួនទន់ភ្លន់ហើយ សម្របទៅតាមគំនិតយោបល់ ឬព័ត៌មានថ្មី។ ពួកគេយល់ថា មិនល្អទេរឿងដែលធ្លាក់ខ្លួនចូលក្នុងឥរិយាបថមិនព្រមស្តាប់អ្វីដែលអ្នកផ្សេងនិយាយ និងមិនព្រមទទួលស្គាល់ថា អ្នកកំពុងតែខ្វះខាតក្នុងការបកស្រាយបញ្ហាពិសេស។

ការបណ្តុះគំនិតត្រូវតែទទួលខុសត្រូវកុំឱ្យមានការឈឺចាប់ក្នុងសង្គម ឬជំលោះក្នុងសង្គម។

ការស្ថិតនៅក្នុងបន្ទប់ ឬនៅកន្លែងណាមួយធំទូលាយបង្គួរ សម្រប-សម្រួលដល់ក្រុមគឺជាការសំខាន់ បើអាកាសធាតុមានអំណោយផល ស្ថិតនៅក្រៅបន្ទប់ជាការល្អដែរការហាត់ពិភាក្សានេះ មិនគប្បីធ្វើនៅកណ្តាល ជាសាធារណៈទេ ព្រោះមិត្តភក្តិរបស់គេដែលមកស្តាប់នោះ ធ្វើឱ្យខូចសកម្មភាព និងដំណើរការទុកចិត្ត ព្រមទាំងការគោរពគ្នានៅក្នុងចំណោមពួកគេ។

*វិន័យនៃការពិភាក្សា*

សូមប្រជុំក្រុមក្នុងកន្លែងណារួចហើយ ពន្យល់ដល់ពួកគេ នូវវិន័យនៃការពិភាក្សាដូចជា :

- អ្នកត្រូវបញ្ជាឱ្យលើកឡើងនូវបញ្ហាសម្រាប់ពិភាក្សា
- អ្នកទាំងឡាយដែលឯកភាពនឹងប្រធានបទត្រូវទៅជុំគ្នានៅកន្លែងម្ខាង (ឧទាហរណ៍ដូចជានៅក្នុងបន្ទប់ខាងស្តាំដៃ)។
- អ្នកទាំងឡាយប្រឆាំងនឹងប្រធានបទពិភាក្សាត្រូវទៅផ្តុំគ្នានៅកន្លែងម្ខាងទៀត។ អ្នកដែលមិនច្បាស់ក្នុងចិត្តមិនអាចគាំទ្រ ឬប្រឆាំងត្រូវស្ថិតនៅចំកណ្តាល។



- ប្រសិនបើមានអ្នកណាម្នាក់ចង់និយាយ អ្នកទាំងនោះ ត្រូវកាន់មីក្រូ "a magic mika" or "magic migrophone" មិនអាចឱ្យនរណាមួយ បន្ទុចបង្អាក់អ្នកដែលកំពុងនិយាយឡើយ។ នៅពេលអ្នកណាមួយ បាន និយាយចប់អ្នកផ្សេងទៀត ដែលចង់និយាយ ត្រូវស្នើសុំមីក្រូភ្លាម។ គ្រូដែល ជាអ្នកបណ្តុះបណ្តាល ត្រូវហុចមីក្រូទៅឱ្យ ពួកគេ នៅជុំវិញតាមសំណើ។
- ប្រសិនបើពួកគេ ត្រូវបានយល់ស្របជាមួយអំណះអំណាង ដែលកាន់តែមាន ច្រើនឡើងៗទាមទារឱ្យពិនិត្យឡើងវិញនូវគំនិតដើមរបស់ពួកគេ ឬទៅ អង្គុយចំកណ្តាល ប្រសិនបើពួកគេមិនសូវប្រាកដ អំពីទស្សនៈរបស់ពួកគេ ដែលគេធ្លាប់ គ្មាននរណាមួយមានអារម្មណ៍ ថាខ្លួនត្រូវបានហាមឃាត់ មិនឱ្យ ផ្លាស់ប្តូរគំនិតឡើយ រឿងនេះមិនមែនជាចំណុចខ្សោយទេ ប៉ុន្តែជាការ បង្ហាញឱ្យឃើញថា ពួកគេសុខ ចិត្តស្តាប់ចំនុចទស្សនៈផ្សេងៗ ហើយជួនកាល ពួកគេអាច ឯកភាព និងចំណុចផ្ទុយពីទស្សនៈរបស់ពួកគេ។

-មិនមានអ្នកឈ្នះ និងអ្នកចាញ់ឡើយ។ ជាជំទាស់មិនមែន មានន័យថា យកប្រៀបលើអ្នកដទៃ ឬប្រមូលមនុស្សឱ្យចូលមកក្នុងក្រុមណាមួយឱ្យបានច្រើន ជាងក្រុមផ្សេងទៀតនោះឡើយ។ មីក្រូទិព្វ "Magic mike ទុកដូចជាមតិ ជំទាស់ ដែលអ្នកត្រូវជ្រើសរើសយកមកថ្លែងតាមមីក្រូនោះ។ រឿងមីក្រូទិព្វនេះគឺ ជាមីក្រូពិតប្រាកដក៏បាន។ រឿងមីក្រូនេះមានន័យថា អនុញ្ញាតឱ្យអ្នកចូលរួម និយាយអំពីបញ្ហាណាមួយ ឬសំដែងនូវគំនិតផ្ទាល់ខ្លួនរបស់គេ។ ការជំទាស់គួរឱ្យ ចង់សើចដែលគេឱ្យឈ្មោះថា មីក្រូ ដែលអ្នកលើកឡើងនោះ មានន័យថា អ្នកបាន បញ្ចូលរឿងសប្បាយរីករាយ ទៅក្នុងការពិភាក្សា។ រឿងសប្បាយនេះធ្វើឱ្យក្រុម ធូរអារម្មណ៍តានតឹង និងធ្វើឱ្យភាពស្និទ្ធស្នាលកាន់តែប្រសើរឡើង។

យើងត្រូវតែយល់ឱ្យច្បាស់ និងម៉ឺងម៉ាត់ចំពោះវិន័យ ដែលមិនអាចឱ្យ នរណាមួយនិយាយដោយគ្មានមីក្រូទិព្វ (របស់អ្វីក៏បាន)កាន់ក្នុងដៃឡើយ។ មាន តែវិធីនេះតែមួយគត់ដែលញ៉ាំងឱ្យអ្នកអាចរក្សារបៀបរៀបរយ។



បានល្អហើយអាចជួយក្រុមឱ្យយល់ថា ត្រូវតែអនុញ្ញាត ឱ្យអ្នកផ្សេងសំដែងមតិរបស់គេតាមលំដាប់លំដោយ ទោះបីពួកគេឯកភាព ឬ មិនឯកភាព ជាមួយនឹងអ្វីដែលគេបាន ឬកំពុងតែនិយាយក៏ដោយ ។ ត្រូវនាំពួកគេឱ្យមានទស្សនៈថា ពួកគេមានសេរីភាពក្នុងការនិយាយស្តីបញ្ចេញមតិ ដូច្នេះពួកគេម្នាក់ៗក្នុងសង្គមនាំគ្នាគិត និងបញ្ចេញមតិដោយផ្សេងៗខ្លួន ដោយគ្មាននរណាមួយត្រូវបានគេប្រកាន់ថា ខុស ឬត្រូវឡើយ ។

*ដំណើរការពិភាក្សា*

នៅពេលម្នាក់បានយល់អំពីទស្សនៈ (Concept) ហើយ អ្នកអាចចាប់ផ្តើមដំណើរការពិភាក្សា :

- អញ្ជើញពួកគេថ្លែងបញ្ចេញមតិ ហើយត្រូវដឹងឱ្យ ប្រាកដថា ម្នាក់ៗបានយល់ច្បាស់នូវមតិនោះ ។
- ត្រូវអញ្ជើញជាបឋមអ្នកដែលចង់ចាប់ផ្តើមការពិភាក្សា បើពុំមានអ្នកចង់ទេ យើងត្រូវលើកទឹកចិត្តជំរុញអ្នកណាម្នាក់ក្នុងក្រុម ឬអ្នកប្រឆាំងឱ្យនិយាយលើកឡើង នូវហេតុផលដែលនាំឱ្យគេ ប្រកាន់យកគោលជំហរពិសេសប្លែកពីគេ ។ ជាការល្អប្រសើរបើមានអ្នកស្ម័គ្រចិត្ត តែបើពុំមានទេយើងត្រូវ ជ្រើសរើសយកអ្នកណាម្នាក់ឱ្យនិយាយ ។
- បន្ទាប់ពីស្តាប់មតិដំបូងរួចហើយ យើងត្រូវហៅនរណាមួយឱ្យមានមតិឆ្លើយតបវិញ ។ យើងហៅអ្នកស្ម័គ្រចិត្តប្រសិនបើមាន ។ យកមីក្រូទិព្វ (របស់ដែលសន្មត) ទៅឱ្យអ្នកស្ម័គ្រចិត្ត ។
- ត្រូវបណ្តោយឱ្យការពិភាក្សាមានដំណើរការដោយរលូនដោយមានកាន់មីក្រូទិព្វជាប់នឹងដៃ ដើម្បីសំដែងមតិ និងបញ្ជាក់ឱ្យដឹងច្បាស់ថា ពួកគេមានការថ្លឹងថ្លែង ល្អណាស់ ក្នុងការគាំទ្រ ឬប្រឆាំង ។
- ត្រូវហៅអ្នកដែលស្ថិតនៅកណ្តាល (មិនគាំទ្រ មិនប្រឆាំង) ឱ្យនិយាយសំដែងមតិបញ្ជាក់មូលហេតុ ដែលនាំឱ្យពួកគេយល់មិនច្បាស់ ។ ត្រូវសួរពួកគេផងដែរថា តើមានមតិយោបល់ណាមួយ ដែលពួកគេបានស្តាប់អាចជួយពួកគេ ឱ្យមានយោបល់ឬទេ? ថាតើ ពួកគេចង់ផ្លាស់ប្តូរកន្លែងពីកន្លែងមួយទៅកន្លែងមួយទៀត ឬទេ?

- ត្រូវបន្តការពិភាក្សាឱ្យស្ថិតនៅក្នុងការរំភើប សប្បាយរីករាយចង់និយាយបញ្ចេញមតិរបស់គេ។ ការពិភាក្សាត្រូវតែបញ្ចប់ នៅពេលដែលក្រុមមានមតិចាកប្រធានដែលត្រូវពិភាក្សា។ យើងត្រូវបញ្ជាក់ជានិច្ចថា គ្មានក្រុមណាត្រូវ ក្រុមណាខុសឡើយ។ ប្រជាពលរដ្ឋម្នាក់មានសិទ្ធិក្នុងការបញ្ចេញមតិ និងទស្សនៈរបស់គេ។ គេអាចប្រកាន់យកគោលជំហរណាមួយ ឬមតិណាមួយតាមសមត្ថភាព នៃការយល់ដឹងរបស់គេ។

យើងអាចទាក់ទាញក្រុមឱ្យចូលរួមការពិភាក្សាតាមមធ្យោបាយ របស់អ្នកផ្ទាល់។ អ្វីដែលចាប់ផ្តើមដំបូង គេត្រូវចាត់ទុកថា ជាសន្ទុះទឹកដែលគេត្រូវតែបើកហើយ។ ម្នាក់អាចនិយាយបន្តបន្ទាប់គ្នា។ ទន្ទឹមនឹងនេះម្នាក់ៗនៅក្នុងក្រុមអាចឆ្លើយចំពោះអ្វីដែលអ្នកមុនបានលើកឡើង។

*ការចាប់ផ្តើមបញ្ចេញមតិ*

ម្យ៉ាងទៀតទិសដៅនៃលំហាត់នេះ គឺជាការជំរុញលើកទឹកចិត្តក្រុមឱ្យលើកឡើងនូវបញ្ហាពលកម្មកុមារ។ ការហ្វឹកហ្វឺនពិភាក្សានឹងប្រសិទ្ធភាពច្រើន ប្រសិនបើអ្នកចាប់ផ្តើមហ្វឹកហ្វឺនដោយផ្តុំនូវប្រធានបទកំប្លែងពីរបញ្ចូលគ្នា ដែលអាចនាំឱ្យក្រុម មានវិធីនិយាយ បញ្ចេញមតិផ្សេងៗគ្នា។ យើងគប្បីបញ្ចូលប្រធានបទ ដែលនាំពួកមានអារម្មណ៍ស្រួល រីករាយ ហើយមិនមានពាក់ព័ន្ធទៅនឹងបញ្ហាពលកម្មទេ។ ដំណាក់កាលដំបូងនៃការហាត់ពិភាក្សា គឺបង្កើតឱ្យមានការទុកចិត្ត និងគោរពគ្នាទៅវិញទៅមកនៅក្នុងក្រុម។

ដោយសារបញ្ចូលនូវអ្វីដែលនាំឱ្យរីករាយ យើងអាចបង្កើតបានភ្លាមនូវឋាមពល និងការទុកចិត្តមិនមានការភ័យខ្លាច។ នៅពេលដែលយើងយល់ថា ក្រុមមានការទុកចិត្ត គ្មានការភ័យខ្លាចហើយនោះ យើងអាចបញ្ចូលប្រធានបទ ស្តីពីពលកម្មកុមារបានហើយ។

ប្រធានបទ ឬមតិដែលយើងត្រូវជ្រើសរើសយកទៅឱ្យពិភាក្សា ត្រូវតែចេញពីបរិបទមួយទៅបរិបទមួយទៀត ព្រោះសៀវភៅនេះ មិនអាចផ្តល់ប្រធានបទច្បាស់លាស់ទៅតាមករណី ឬសំណូមពរបានឡើយ។ យើងត្រូវតែសរសេរ ឬបង្កើតប្រធានបទ សម្រាប់ចាប់ផ្តើម ការពិភាក្សាជូនដល់ក្រុម។ ប្រធានបទទាំងនោះ ត្រូវពាក់ព័ន្ធទៅនឹងវប្បធម៌ ប្រពៃណី សង្គម និងកត្តាផ្សេងទៀត។ នៅពេលធ្វើការសម្រេចចិត្តទៅលើប្រធានបទមួយ វាជាការប្រសើរ ការផ្តោតអារម្មណ៍ ទៅលើរឿងរ៉ាវដែលទាក់ទងទៅនឹងជីវភាពនៃក្រុមឧទាហរណ៍ដូចជា : ប្រសិនបើមានវង់ភ្លេងប្រជាប្រិយជាក់លាក់មួយ ឬបទភ្លេង rick ដែលមានប្រជាប្រិយភាពខ្លាំង ក្នុងសង្គមរបស់អ្នកអាចនាំឱ្យមានការ អ្នកអាចថ្លែងបញ្ចេញដូចជា :



ឈ្មោះ និងក្រុមពិភាក្សាគឺជាក្រុមភ្លេងដែលប៉ិនប្រសប់ ហើយបង្កើនប្រាក់ចំណូលពិតន្ត្រីក្នុងប្រទេសរបស់ពួកគេ។ សមាជិកខ្លះនៃក្រុមនឹងស្រឡាញ់ក្រុម អ្នកខ្លះទៀតនឹងមិនស្រឡាញ់ក្រុមឡើយ។ ទោះយ៉ាងណាក៏ដោយពួកគេនឹងមានបញ្ហាតិចតួច ក្នុងការសំដែងមតិដោយខ្លួនឯង ស្តីពីបញ្ហាដែលនាំឱ្យពួកគេទទួលនូវលទ្ធផលមិនល្អដែលបណ្តាលមកពីការក្តៅក្រហាយ ឬមកពីសត្រូវ។ ប្រសិនបើមាន ក្រុមកីឡាដែលមានប្រជាប្រិយខ្លាំង ក្នុងប្រទេសរបស់អ្នក ឬក្នុងតំបន់ណាមួយ អ្នកគប្បីចាប់ផ្តើមការពិភាក្សាថ្លែងមតិ ភ្ជាប់ទៅនឹងក្រុមកីឡាពិសេសនោះ។ អ្នកគប្បីបែងចែកមនុស្សបង្កើតជាក្រុម ប៉ុន្តែកុំឱ្យមានការភ័យខ្លាច ឬមានការគំរាមកំហែង។ យើងត្រូវដឹកនាំឱ្យមានការថ្លែងបញ្ចេញមតិឱ្យបានច្រើន ប៉ុន្តែកុំនាំឱ្យមានការតានតឹងចូលទៅក្នុងក្រុម យើងត្រូវបញ្ចូលអ្វីដែលរីករាយទៅក្នុងការហាត់សំដែងមតិនោះ។

*បញ្ហាគន្លឹះ*

នៅពេលយើងដឹងច្បាស់ថា ក្រុមបានយល់ច្បាស់ ហើយចូលរួម ក្នុងការពិភាក្សាហើយនោះ យើងគប្បីបញ្ចូលបញ្ហាគន្លឹះសម្រាប់ការពិភាក្សា ខាងក្រោមនេះគឺជាការថ្លែងមតិខ្លះ ស្តីពីបញ្ហាពលកម្មកុមារ។

ការថ្លែងបញ្ចេញមតិនេះ គឺជាការប្រលងប្រណាំងរបស់បុគ្គល តាមរបៀបផ្សេងៗ។

តាមការពិតពួកគេ ចូលជជែកជំទាស់ដើម្បីជំរុញឱ្យមានប្រតិកម្ម។ រឿងនេះអាចធ្វើឡើង ដោយមានត្រួតពិនិត្យប្រកបដោយការសប្បាយរីករាយ។ ឧទាហរណ៍ដូចជាមតិដែលពោលថា "នារីត្រូវនៅផ្ទះ" ធ្វើឱ្យមានប្រតិកម្មយ៉ាងខ្លាំងពីសំណាក់នារី។ ទិសដៅមិនមែនមានន័យថា បញ្ចុះឱ្យថា តាមទេ ក៏ប៉ុន្តែនាំឱ្យក្រុមបង្ហាញគោលជំហរ និងការយល់ឃើញរបស់ពួកគេ។ នេះជារឿងដែលផ្តល់ព័ត៌មាន និងជំរុញឱ្យមានការពិភាក្សាយ៉ាងស្មោះត្រង់ក្នុងចំណោមពួកគេ។ នេះជាវិធីសាស្ត្រពង្រឹង ក្រុមនិងបង្កើនថាមពល របស់ពួកគេ។ ការពិភាក្សាលើកមុនផ្អែកទៅលើការបញ្ចេញមតិប្រកបដោយការសប្បាយ។ ការពិភាក្សាបន្តមកទៀត គឺជាលំហាត់ដែលមានភាពមធ្យ័តបន្តិច។ ប៉ុន្តែការពិភាក្សាត្រូវបើកចំហរតាមលទ្ធភាព ការពិភាក្សា និងវិធីពិភាក្សា វិធីស្តាប់ និងគោរពគ្នាទៅវិញទៅមក គឺជាបញ្ហាចំបង (ច្បាស់លាស់) ដំណាក់កាលនេះដោយប្រុងប្រយ័ត្ន ហើយគោរពមតិ របស់ក្រុមទាំងសង្ខាង។ ប្រសិនបើមានការពិភាក្សាចាកប្រធានគ្រប់គ្រងលែងបាន អ្នកត្រូវរំលឹកក្រុមថា ការពិភាក្សាមិនត្រូវបានកាត់សេចក្តីទេ។ ត្រូវតែគោរពអ្វីដែលខ្វែងគំនិតគ្នា។ ការថ្លែងមតិគប្បីមាន ដូចតទៅ :

ក-ការថ្លែងបានផ្តល់នូវយោបល់ខ្លះៗរួមមាន :

- ស្ត្រីត្រូវ នូវផ្ទះ
- បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាចំពោះការងារ
- សូមឱ្យក្មេងប្រុស និងក្មេងស្រី សិក្សានៅក្នុង សាលារៀនឱ្យបានយូរ ហើយមិនធ្វើការឡើយ"
- សូមឱ្យក្មេងប្រុសស្រីធ្វើការប្រសិនបើគេចង់ធ្វើ
- គប្បីឱ្យក្មេងប្រុសស្រីធ្វើការប្រសិនបើជីវិតរបស់គេ អាចរស់នៅបានដោយសារការងារ។

ត្រូវបង្កើតល័ក្ខខ័ណ្ឌការងារសមស្របសម្រាប់កុមារសកម្មភាពទី២: ការពិភាក្សាផ្លូវការ

- ការបង្រៀន ២ពេលដាច់ពីគ្នា និងការបង្រៀន ២ពេលបន្តគ្នាដោយបន្ថែមការស្រាវជ្រាវ ការរៀបចំនិងពេលវេលាស្រាវជ្រាវ

ដំណាក់កាលដំបូងនៃការពិភាក្សាជាផ្លូវការ គឺត្រូវបង្កើតប្រធានបទ ឬគោលជំហរ សម្រាប់ឱ្យក្រុមទាំង២ បញ្ចេញមតិ។ ប្រធានបទនេះ ត្រូវផ្សារភ្ជាប់ទៅនឹងពលកម្មកុមារ។ មានជំរើស ២យ៉ាង :



-ជំរើសទី១ មិនសូវមានការចាប់អារម្មណ៍ទេ។ ជំរើសនេះកើតឡើងដោយយកគំនិតផ្ទាល់ខ្លួនរបស់អ្នក ឬធ្លាក់ចូលទៅក្នុងការពិភាក្សាជាក្រុមទី៣។

## សកម្មភាព ៤ ការពិភាក្សាជាផ្លូវការ

គឺមានការចាប់អារម្មណ៍ខ្លាំងណាស់ ព្រោះមានការសប្បាយ ហើយរក្សាគោលការណ៍ប្រជាធិបតេយ្យ និងវិធីសាស្ត្រ គរុកោសល្យ។ ជំរើសទី២នេះមានគោលបំណងរៀបចំការសំដែងមតិឱ្យបានផុសផុលនៅក្នុងក្រុមទាំងមូល ជុំវិញប្រធានបទដែលអាចលើកឡើងបាន។

ការលើកឡើងនូវប្រធានបទជាច្រើនអាចពង្រឹងសមត្ថភាពរបស់អ្នកឱ្យចេះរៀបចំការពិភាក្សា និងមានសមត្ថភាពយល់ដឹងថា ក្រុមបានចូលពាក់ព័ន្ធនឹងលំហាត់នេះ។ ប្រធានបទ ដែលយកមកប្រើដូចគេនោះ ក្នុងដំណាក់កាលសាកល្បងនៃម៉ូឌុលនេះគឺ "កុមារត្រូវទៅសាលារៀន មិនត្រូវទៅធ្វើការទេ"។ រឿងនេះមិនមែនជាបញ្ហាពឹងផ្អែកទៅមតិដែលពោលថា កុមារកើតមកសម្រាប់ធ្វើការ។ ក្រុមដែលសំដែងមតិប្រឆាំងនឹងគំនិតខាងលើនេះ ជាអ្នកឈ្នះ ក្នុងការពិភាក្សា។ ពេលនោះគ្រុមពិភាក្សានៅចំពោះមុខ អ្នកស្តាប់និងអ្នកវិនិច្ឆ័យក៏នាំកុមារចេញពីកន្លែងធ្វើការ ដោយមិនលុបចោលបញ្ហាក្រខ្សត់,ការខ្វះការងារធ្វើ,ការខ្វះការអប់រំ ដោយដាក់កំហុសទៅលើពលកម្មកុមារ និងគ្រួសាររបស់ពួកគេ។

បន្ទាប់ពីឯកភាពជាមួយក្រុមទៅលើប្រធានបទដែលត្រូវបានជ្រើសរើស សម្រាប់លំហាត់ពិភាក្សាមក,ដំណាក់កាល

### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

មេរៀនពិភាក្សាអាចមានរយៈពេលវែង។ ប្រសិនបើអ្នករៀបចំការប្រកួតប្រជែង ការពិភាក្សានឹងមានរយៈពេលវែង។

អ្នកត្រូវធ្វើផែនការបង្រៀនដោយប្រុងប្រយ័ត្ន ដោយធ្វើយ៉ាងណាកុំទុកអ្នកណាម្នាក់នៅស្ងៀមមិនធ្វើអ្វីសោះ នៅពេលអ្នកផ្សេងកំពុងតែធ្វើការស្រាវជ្រាវ និងរៀបចំការថ្លែងបញ្ចេញមតិ។

អ្នកត្រូវជ្រើសរើសយកប្រធានបទណាមួយសម្រាប់ក្រុមពិភាក្សា រួចត្រូវរៀបចំឧទាហរណ៍ ៣ ក្រុមជាអ្នកគាំទ្រ ហើយ៣ក្រុមទៀត ជាអ្នកប្រឆាំង។ ក្រុមនីមួយៗត្រូវដកខ្លួនទៅរៀបចំធ្វើការស្រាវជ្រាវ និងសរសេរនូវអ្វីដែលពួកទទួលបន្ទុកត្រូវតែមានការប្រលងប្រណាំង ប៉ុន្តែម្នាក់ត្រូវសរសេរ និងសម្តែងបញ្ចេញមតិទៅតាមបែបបទផ្ទាល់ខ្លួនរបស់គេ។

បន្ទាប់តម្រូវឱ្យចាត់តាំងក្រុមពិភាក្សា។

ប្រសិនបើអ្នកស្គាល់ច្បាស់បុគ្គលដែលពូកែបញ្ចេញមតិពិភាក្សា ហើយអ្នកដឹងច្បាស់ថា អ្នកទាំងនោះមិនស្ថិតនៅក្នុងក្រុមតែមួយឡើយ។ ការស្ថិតនៅក្នុងក្រុមនីមួយៗ អ្នកពូកែបញ្ចេញមតិពិភាក្សា និងញ៉ាំងឱ្យអង្គប្រជុំទាំងមូល មានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការពិភាក្សា។

*ការរៀបចំក្រុមពិភាក្សា*

ក្រុមពិភាក្សាគួរតែប្រជុំគ្នាដើម្បីពិភាក្សាជ្រើសរើសយុទ្ធសាស្ត្រនិងជ្រើសរើសយកតំណាង ដែលត្រូវស្រាវជ្រាវ និងសរសេរចំលើយសម្រាប់ឆ្លើយតបទៅនឹងមតិជំទាស់។

ការសរសេរចំលើយគឺជាឱកាស ចាប់ផ្តើមបញ្ចូលនូវអ្វីដែលនាំឱ្យ មានការសប្បាយរីករាយ។ ប្រសិនបើអ្នកប្រាថ្នាឱ្យមានការសប្បាយរីករាយ ក្នុងការពិភាក្សា អ្នកអាចបង្ហាញឧបសម្ព័ន្ធទី១ ដល់អ្នកពិភាក្សា ដើម្បីជួយពួកគេឱ្យ យល់អំពី តួនាទីរបស់គេ ព្រមទាំងការទទួលខុសត្រូវរបស់ពួកគេ។ អ្វីៗទាំងអស់ អាស្រ័យដោយការគោរពដ៏ម៉ត់ចត់នូវវិន័យនៃការពិភាក្សា និងត្រូវធានាឱ្យ យល់ច្បាស់ថា មេរៀននេះត្រូវបានអនុវត្ត។

អ្នក និងធនធានមនុស្សមកពីក្រៅក្រុម មានតួនាទីសំខាន់ណាស់ នៅក្នុងដំណាក់កាលនេះ។ ក្រុមការងារទាំងនេះត្រូវការការគាំទ្រ ដើម្បីសរសេរ យុទ្ធសាស្ត្រដើម្បីដឹងរបៀបឆ្លើយតបទៅនឹងមតិជំទាស់ ដើម្បីស្រាវជ្រាវរក ប្រធានបទ និងសរសេររួចចែកចាយនូវមតិរបស់ខ្លួន។ ក្រុមពិភាក្សានីមួយៗ គប្បីស្ថិតនៅក្នុងបរិយាកាសសុខសាន្ត បានសេចក្តីថា ពួកគេអាចចេញទៅក្រៅបន្ទប់ ប្រសិនបើអាកាសធាតុល្អ ឬធ្វើការក្នុងបណ្ណាល័យ ក្នុងបន្ទប់រៀន ឬបែងចែកបន្ទប់នោះ ជាកន្លែងតូចៗសម្រាប់ក្រុមពិភាក្សា។ ការផ្តល់គំនិត យោបល់ត្រូវតែមានប្រយោជន៍។ ការផ្តល់យោបល់នេះ មិនត្រូវអនុវត្តតាម ឱ្យបានល្អឥតខ្ចោះនូវវិន័យនៃការពិភាក្សានោះទេ។ សូមអនុវត្តផ្នែកណាមួយនៃ វិន័យដែលអ្នកយល់ថា ល្អ។

*យុទ្ធសាស្ត្រ* : ត្រង់ចំណុចនេះក្រុម ត្រូវការទទួលការណែនាំ អំពីរបៀបធ្វើការស្រាវជ្រាវ របៀបសរសេរ របៀបបង្ហាញមតិយោបល់ដល់ការពិភាក្សា។ ជាការសំខាន់ណាស់ រឿងដែលអ្នកនិយាយម្នាក់ៗមានការគិត យល់ឃើញអំពី

អ្វីៗដែលក្រុមរបស់គេនឹងពោលលើកឡើង ។

ការលើកឡើងនូវរឿងដដែលៗដូចគ្នា មិនមែនជាគំនិតល្អ ហើយធ្វើឱ្យអ្នកវិនិច្ឆ័យ ឬអ្នកស្តាប់ធុញទ្រាន់ ។

ចូរលើកទឹកចិត្តជំរុញក្រុមឱ្យពិនិត្យប្រធានបទឱ្យបានច្បាស់លាស់ ហើយសាកល្បងបំបែកប្រធានបទនោះ ជាចំណុចតូចៗ ដើម្បីឱ្យគេគាំទ្រ ក៏ដូចឱ្យគេប្រឆាំង ។

យុទ្ធសាស្ត្រល្អ គឺត្រូវឱ្យសមាជិកក្រុមនីមួយៗ ផ្តោតទៅលើចំណុចនីមួយៗនៃការស្រាវជ្រាវ ឬពង្រាងរបស់គេ ដោយធ្វើយ៉ាងណា ឱ្យពួកគេអាចនិយាយហូរហែបន្តបន្ទាប់គ្នា ហើយរកករណីផ្សេងៗដើម្បី រក្សាគោលជំហររបស់គេ ។ មានអ្នកពូកែនិយាយបញ្ចេញមតិ ក៏ជាការប្រសើរណាស់ ព្រោះអាចបង្កើតឱ្យមានឥទ្ធិពល និងផលប៉ះពាល់បានច្រើន ។

▪ *ការឆ្លើយតប* : សមាជិកនៃក្រុមអាចមានឱកាស ឆ្លើយតបទៅចំពោះករណីណាមួយ ដែលត្រូវលើកឡើងដោយក្រុមជំទាស់ ។ ក្រុមអាចមានគំនិតល្អៗទប់ទល់ និងមតិយោបល់របស់ក្រុមជំទាស់ ហើយក្រុមអាចត្រៀមគម្រោងចំលើយសម្រាប់ឱ្យសមាជិករបស់ក្រុមឡើងឆ្លើយតប ។

▪ *ការស្រាវជ្រាវ និងធ្វើពង្រាង* គម្រោងចំលើយត្រូវលើកឡើងដោយសមាជិកណាមួយ ហើយត្រូវធ្វើយ៉ាងណា ឱ្យក្រុមជំទាស់យល់ថា ជាគំនិត ឬការស្រាវជ្រាវ និងការធ្វើពង្រាងបន្ទាប់ពីការពិភាក្សាថា តើនរណាត្រូវនិយាយអ្វីមកជំហានបន្ទាប់ គឺតម្រូវឱ្យសមាជិកបុគ្គល នៃក្រុមចាប់ផ្តើមស្រាវជ្រាវរកមតិយោបល់ទាំងនោះ ពេលវេលាមធ្យម សម្រាប់ថ្លែងគឺមាន ៣ ឬ៥នាទីប៉ុណ្ណោះ ។ រយៈពេល ៥នាទីជារយៈពេលវែងណាស់ទៅហើយ សម្រាប់និយាយចំពោះមុខអ្នកស្តាប់ ។ ត្រូវបញ្ជាក់ប្រាប់ក្រុមឱ្យ និយាយបានខ្លី ហើយឱ្យចំចំណុចសំខាន់ៗ ។

▪ *ការប្រគល់លទ្ធភាព* នេះជាការបណ្តុះបណ្តាលហ្វឹកហ្វឺនខ្លួនគេផ្ទាល់ ហើយ សមាជិកនៃក្រុមរបស់អ្នក ប្រាកដជាត្រូវការជំនួយនៅពេលនេះ ។ តាមការពិតនៅត្រង់ចំណុចនៃការបណ្តុះបណ្តាលនេះ អ្នកត្រូវរកតួសំដែង ដែលអាចនិយាយបានតាមបែបធម្មជាតិនៅក្នុងក្រុមរបស់អ្នក ។ ការនិយាយបែបធម្មជាតិ



មានសារៈសំខាន់ដូចការ ថ្លែងមតិយោបល់អញ្ចឹងដែរ។ ដូច្នេះសមាជិកនៃក្រុម ត្រូវហាត់និយាយ និងសំដែងកាយវិការផង។

នេះជាឱកាសមួយល្អ ក្នុងការបង្រៀនពួកគេ ឱ្យចេះសរសេរ ពង្រាងថ្លែងមតិយោបល់សរសេរ មើលគេឱ្យបានច្បាស់លាស់ រួចហើយបង្រៀនឱ្យសរសេរ ឃ្លាខ្លីៗដូចប័ណ្ណអក្សរ សម្រាប់អ្នកនិយាយ (សូមមើល ឧបសម្ព័ន្ធ មួយ)។

ពួកគេគួរតែចៀសវាងការអាន ២-៣ ទំព័រយ៉ាងលឿន ដោយគ្មានការ ដកដង្ហើមដោយឈរនៅចំពោះមុខអ្នកស្តាប់ទាំងឡាយ។ មូលដ្ឋាននៃការនិយាយ ជាសាធារណៈរួមមាន : សំលឹងមើលអ្នកស្តាប់ ដើម្បីបង្កើតនូវទំនាក់ទំនងផ្ទាល់ ការនិយាយឱ្យច្បាស់ហើយយឺតៗសម្រាកបន្តិចបន្តួច ចំណុចសំខាន់ៗ និយាយតិចៗ ហើយដង្ហើមតាមធម្មជាតិ ការនិយាយដូចនេះ នាំឱ្យសមាជិកក្រុម ដែលបានគាំទ្រការអនុវត្តន៍ អាចនិយាយជាមួយអ្នកដទៃទៀត តាមរបៀបនេះឱ្យបានល្អប្រសើរ។ ប្រសិនបើពួកគេធ្វើការហ្វឹកហ្វឺនតែម្នាក់ឯង ពួកគេគួរតែធ្វើនៅមុខកញ្ចក់។ ពួកគេគួរតែមានពេលវេលាកំណត់ផងដែរ ក្នុងការថ្លែងផ្សេងៗ។ នេះជាមធ្យោបាយ ល្អដែលនាំឱ្យសមាជិកគាំទ្រ នូវការហ្វឹកហ្វឺន ក្នុងក្រុមនីមួយៗការពង្រឹងចំណងរវាងសមាជិកក្រុមធ្វើឱ្យពួកគេទុកចិត្តទៅលើការងារទាំងអស់ ឆ្ពោះទៅគោលដៅដូចគ្នា។

*ការពិភាក្សា*

ជាមួយក្រុមទាំងមូល ត្រូវរៀបចំបន្ទប់កន្លែងណា ដើម្បី ធ្វើការពិភាក្សា។ បន្ទប់មួយណាដែលអាចពិភាក្សាបានល្អ គឺបន្ទប់ណាដែលអ្នកតែងតែបានធ្វើការជាមួយក្រុម។ អាស្រ័យដោយលក្ខខ័ណ្ឌនៃអាកាសធាតុ អ្នកអាចសម្រេច ធ្វើការពិភាក្សានៅក្រៅបន្ទប់ក៏បាន។ ប្រសិនបើអ្នកមានជោគវាសនាច្រើន អ្នកនឹងអាចប្រើប្រាស់នូវបន្ទប់ដ៏ធំ ហើយរៀបចំកៅអី សម្រាប់អ្នកស្តាប់ ជ្រើសរើសតុមួយសម្រាប់ការកាត់សេចក្តី និងតុនៅខ្ពស់សម្រាប់ក្រុមពិភាក្សា និង គណៈធិបតី។



ជាការប្រសើរប្រសិនបើអ្នកធ្វើជាគណៈអធិបតី អ្នកនឹងស្គាល់ចំពោះបុគ្គលនៅក្នុងក្រុមទាំងនោះ ហើយត្រូវបានគេស្គាល់ជាមួយអ្វីៗ ដែលបុគ្គលកំពុងតែមានប្រសាសន៍។ ទោះបីយ៉ាងណាក៏ដោយសម្រាប់ដំណើរការអប់រំ អ្នកត្រូវអញ្ជើញអ្នកណាម្នាក់ធ្វើជាអធិបតីក្នុងការពិភាក្សា។ ជាឧទាហរណ៍ប្រសិនបើអ្នក កំពុងការ

អប់រំក្នុងប្រព័ន្ធ សាលាអាចយល់ព្រមទទួលតួនាទីទាំងនេះ។ ម្យ៉ាងទៀត ប្រសិនបើអញ្ជើញអ្នកស្តាប់ឱ្យបានច្រើនលើសលុប ហើយឱ្យគេចូលរួមហេតុអ្វីបានជាមិនស្នើអ្នកនយោបាយតាមតំបន់ ក្រុមប្រឹក្សាសាលា អង្គការក្រៅរដ្ឋាភិបាល ឬការិយាល័យពាណិជ្ជកម្មសហប្រជាជាតិ ឬអ្នកដឹកនាំសហគមន៍ រឺឪពុកម្តាយ ឱ្យចូលរួម ជាអធិបតី? នេះគឺជាមធ្យោបាយបញ្ចូលសហគមន៍ទៅក្នុងដំណើរការនៃគរុកោសល្យ។

ប្រសិនបើអ្នកអញ្ជើញអ្នកណាមួយជាអធិបតី សូមពិចារណាដល់ការតំណាងប្រព័ន្ធផ្សព្វផ្សាយនៅតាមមូលដ្ឋាន ដើម្បីឱ្យគេធ្វើរបាយការណ៍ផ្សព្វផ្សាយអំពីការពិភាក្សា។ នៅពេលអ្នកស្តាប់អ្នកវិនិច្ឆ័យ និងក្រុមពិភាក្សា អញ្ជើញដល់កន្លែង ហើយគណៈអធិបតីត្រូវចាប់ធ្វើសម័យប្រជុំ ហើយជំរាបអ្នកស្តាប់ឱ្យបានដឹង អំពីប្រធានបទពិភាក្សា ប្រសិនបើអ្នកមិនមែនជាអធិបតីនៃការប្រជុំទេ អ្នកត្រូវមានកំណត់ត្រា សង្ខេបមួយដើម្បីផ្តល់ទៅឱ្យអ្នកដែលកំពុងទទួលតួនាទីជាអធិបតី។ គណៈអធិបតីត្រូវធ្វើការបង្ហាញឈ្មោះសមាជិកក្នុងម្តងមួយៗ ហើយអញ្ជើញពួកគេទៅវេទិកាដើម្បីនិយាយ។ តាមទម្លាប់ចំណុចសំខាន់ៗនៃការថ្លែងយោបល់ ត្រូវតែបានសង្ខេបមុនពេល ជូនវេទិកាទៅឱ្យម្នាក់ទៀតថ្លែងសុន្ទរកថា បញ្ចេញមតិ។ អ្នកជាអធិបតីត្រូវតែផ្លាស់ប្តូរអ្នកនិយាយបានសេចក្តីថា បើកឱកាសឱ្យអ្នកនិយាយគាំទ្រ រួចបន្ទាប់មកឱ្យអ្នកនិយាយប្រឆាំងប្រធានបទ។

ការបកស្រាយអំពីវិធានការណ៍ នៃការពិភាក្សានៅតាមតំបន់ត្រូវបញ្ជាក់អំពីរបៀបដែលអំណះអំណាងដែលត្រូវបានលើកជំទាស់។ ឧទាហរណ៍ការអនុវត្តន៍មួយដែលអ្នកនិយាយនីមួយៗ ចំណាយពេលវេលាក្នុងការបដិសេធអំណះអំណាង របស់អ្នកបកស្រាយមុននេះពីក្រុមផ្សេងៗគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងការអនុវត្តន៍ដទៃទៀត (ពេលខ្លះងាយស្រួលនិយាយជាមួយយុវជនទាំងនោះ) អ្នកដឹកនាំត្រូវរង់ចាំរហូតដល់នរណាបានឡើងថ្លែងសុន្ទរកថាចប់ ហើយអញ្ជើញ តំណាងម្នាក់ពីក្រុមផ្សេងទៀតឱ្យឆ្លើយជំទាស់នឹងការថ្លែងរបស់ក្រុមមុននេះ។ (អ្នកតំណាងទាំងនេះ ត្រូវជ្រើសរើសដោយក្រុមនីមួយៗទុកជាមុន)។

ម្យ៉ាងវិញទៀត អ្នកដឹកនាំទាំងនោះគួរតែសង្ខេបនូវកិច្ចពិភាក្សានៃក្រុមនីមួយៗជូនដល់អ្នកស្តាប់ និងអ្នកកាត់សេចក្តីអាស្រ័យទៅលើអ្វីដែលខ្លួន និងក្រុមបាន

យល់ព្រម។ វេទិកាត្រូវតែបើកចំហដើម្បីទទួលសំណួរ និងអនុសាសន៍ពីអ្នកស្តាប់។ ចំនួនសំណួរ និងអន្តរកម្មជាមួយក្រុមអ្នកស្តាប់មិនត្រូវឱ្យលើសពេលវេលាឡើយ។ ពីព្រោះការប្រើពេលវេលាវែងហួសហេតុ នាំឱ្យគេធុញទ្រាន់។ ត្រូវឃ្លាំមើលក្រុមពិភាក្សានេះ ហើយមើលពួកគេតាមការចាំបាច់។

ក្នុងកំឡុងពេលនៃសកម្មភាពទាំងនេះ ក្រុមនៃអ្នកកាត់សេចក្តីគួរតែធ្វើការពិភាក្សា ពីការ ថ្លែងរបស់ក្រុម ក្នុងចំណោមពួកគេទាំងអស់។

ពួកគេអាចធ្វើការប្រជុំគ្នាក្រៅផ្លូវការ "ការប្រមូលផ្តុំ"នៅចុងបញ្ចប់នៃសុន្ទរកថា ថ្លែងមតិ រឺពួកគេអាចអនុវត្តតាមវិន័យមួយនៅក្នុងឧបសម្ព័ន្ធមួយ ដែលនៅក្នុងនោះ ដែលអ្នកនិយាយ នីមួយៗទទួលបានពិន្ទុ ១០០ អាស្រ័យទៅលើ "សាច់រឿង" វិធីសាស្ត្រ និងរបៀប"។

នៅទីបញ្ចប់អ្នកដឹកនាំ គួរតែហៅអ្នកនាំពាក្យរបស់ក្រុម ការកាត់សេចក្តីឱ្យរាយការណ៍សង្ខេបរឿងទាំងអស់ឡើងវិញ ដើម្បីបង្ហាញទិដ្ឋភាពនៃការពិភាក្សា និងកំណត់ក្រុមដែលទទួលបានជោគជ័យ។ អាស្រ័យទៅលើអ្នកដែលបានចូលរួមក្នុងក្រុមទាំងនោះ អ្នកអាចជ្រើសរើសយកអ្វីដែលជាចំណុចសំខាន់ៗបញ្ចូលទៅក្នុងមេរៀនទាំងនេះ ហើយផ្តល់នូវពានរង្វាន់ចំពោះក្រុម ដែលឈ្នះនៅក្នុងការពិភាក្សានីមួយៗ។ អ្នកអាចដឹងអំពីប្រតិកម្មនៃក្រុម ចំពោះការប្រកួតទាំងនោះ។ ប្រសិនបើមានអ្វីដែលមិនល្អយើងមិនត្រូវលើកបង្ហាញរឿងនោះឡើយ។ ប្រសិនបើវាមានការសប្បាយ និងការបង្កើតឱ្យមានភាពរីករាយសម្រាប់ក្រុមយើងត្រូវលើកបង្ហាញរឿងនេះជំរុញលើកទឹកចិត្ត ដល់ក្រុមពិភាក្សា ឱ្យផ្តោតទៅលើគុណភាពនៃការងាររបស់ពួកគេ។

អាស្រ័យដោយអ្នកដែលត្រូវបានគេអញ្ជើញឱ្យចូលរួមស្តាប់ ក្នុងនោះមានឪពុកម្តាយ គ្រូបង្រៀន និងអ្នកដទៃផ្សេងទៀត។ ប្រសិនបើមានធនធាន យើងអាចរៀបចំឱ្យភេសជ្ជៈ បន្ទាប់ពីការពិភាក្សារួច។ ការរៀបចំនេះមានសារៈសំខាន់ណាស់ប្រសិនបើការពិភាក្សាត្រូវធ្វើអស់រយៈពេលយូរ

ហើយប្រសិនបើអ្នកចង់ជំរុញអោយមានឆ្លងឆ្លើយគ្នាក្នុងក្រុមរវាងពួកអ្នក និងអ្នកស្តាប់។ វាមានសារៈសំខាន់ណាស់ ក្នុងការសម្រួលសកម្មភាពរវាងក្រុមរបស់អ្នក និងមនុស្សដែលមានឋានៈស្មើៗគ្នា និងជាគន្លឹះសម្រាប់ឱ្យបុគ្គលម្នាក់ៗពីសហគមន៍ចូលរួមទទួលការអប់រំ និងជួយយុវជនរបស់អ្នកឱ្យទទួលបន្ទុកជាភ្នាក់ងារសម្រាប់ផ្លាស់ប្តូរសង្គម។

ការរៀបចំភេសជ្ជៈ គឺជាគំនិតមួយដ៏ល្អប្រសិនបើមានការ ចូលរួមអង្គការ ពីអ្នកនយោបាយតាមតំបន់ពីអ្នកតំណាងសាលារៀន ឬអាជ្ញាធរ។ក្រុមទាំងនេះអាចធ្វើការណែនាំឱ្យហាត់រៀនធ្វើការពិភាក្សា និងវិធីសាស្រ្តសំរាប់ពង្រឹងគោលដៅនេះ ត្រូវតែយកមកប្រើ។ អ្នករាយការណ៍ដោយសរសេរ ឬផ្សព្វផ្សាយព័ត៌មានតាមវិទ្យុ ឬទូរទស្សន៍តែងតែមានការទទួលគាំទ្រដល់អត្ថបទរបស់ពួកគេ ហើយអត្ថបទនេះត្រូវស្តែងចេញពីការពិភាក្សារួមរបស់ក្រុមបន្ទាប់ពីការហ្វឹកហាត់រួចហើយ។

## សកម្មភាព ៣
## ការប្រកួតប្រជែងនៃការពិភាក្សា



*ការសម្រេចចិត្ត :* ពេលវេលាត្រូវកំណត់ទៅតាមចំនួនដែលបានចូលរួម។ អ្នកគួរតែបង្កើតការប្រកួតប្រជែងឱ្យបានទូលំទូលាយជាងនេះរហូតដល់អ្នកអាចទាក់ទងបង្កើតឡើងនូវសកម្មភាពក្នុងការពិភាក្សា។ ប្រសិនបើមានការពិភាក្សា ដែលអ្នកកំពុងស្ថិតនៅក្នុងនេះ អ្នកត្រូវធ្វើការណែនាំ បញ្ចូលបញ្ហាពលកម្មកុមារ ធ្វើជាប្រធានបទសម្រាប់ពិភាក្សាជាបន្តបន្ទាប់។ ការពិភាក្សាបែបនេះ មានលក្ខណៈត្រូវចំណេញ ប៉ុន្តែត្រូវតែញុំាងមេរៀននេះ ឱ្យមានការចាប់អារម្មណ៍ខ្លាំង ដោយប្រើមធ្យោបាយជាច្រើន។ អាស្រ័យដោយការចាប់ផ្តើមមួយ ដែលអ្នកកំពុងតែធ្វើឧទាហរណ៍ការអប់រំក្នុងប្រព័ន្ធ ឬក្រៅប្រព័ន្ធ អ្នកអាចថ្លែងមតិបើកការប្រកួតប្រជែង ជូនដល់អ្នកដទៃទៀតដែលធ្វើការក្នុងស្ថាប័ន ណាមួយដែលអ្នកកំពុងតែធ្វើការងារនៅឯណា? ម្យ៉ាងទៀតការងារអាចលើកកំពស់ឥទ្ធិពលនៃការប្រមូលផ្តុំសហគមន៍ ហើយធ្វើឱ្យមានការយល់ដឹងកាន់តែប្រសើរឡើង អំពីបញ្ហាពលកម្មកុមារ។

សម្រាប់ការពិភាក្សា ប្រកួតប្រជែងគ្នា អ្នកត្រូវតែធ្វើផែនការដោយប្រុងប្រយ័ត្ន : ជ្រើសរើសយកក្រុមនៃអ្នកកាត់សេចក្តី ចុះបញ្ជីអ្នកគាំទ្រ ដែលត្រូវជួយក្នុងការស្រាវជ្រាវ ការហាត់ហ្វឹកហ្វឺន ដឹកនាំការពិភាក្សា ការជ្រើសរើសគណៈអធិបតី ការរៀបចំសវនាការ និងរៀបចំប្រធានបទ សម្រាប់ពិភាក្សា។

គំនិតពិភាក្សាគួរតែបង្កើត ឱ្យមានការជំទាស់ តវ៉ានៅក្នុងក្រុម ពិភាក្សា និងប្រកួតប្រជែង ដើម្បីឱ្យមានការរីកលូតលាស់ឱ្យបានប្រសើរ។ ការពិភាក្សាដោយមានការជំទាស់តវ៉ា រវាងក្រុមទីមួយៗរហូតដល់រវាងក្រុមទីពីរ ការប្រកួតប្រជែងរបៀបនេះបានកើតមានរួចហើយ នៅក្នុងបរិបទជាច្រើន និងប្រទេសជាច្រើន។ ទោះបីជាយ៉ាងណា ក៏ដោយគំនិតនៃយុទ្ធសាស្ត្រទាំងនេះ មានគោលដៅជួយពង្រឹងការយល់ ដែលពាក់ព័ន្ធទៅនឹងគោលដៅនៃក្រុមធំ ក្នុងការហាត់ហ្វឹកហ្វឺន។

អ្នកនឹងត្រូវបានរៀបចំដើម្បីសាកល្បងហាត់ហ្វឹកហ្វឺន ហើយការងារនេះ

មានសារៈសំខាន់។ អ្នកគួរតែធ្វើផែនការបូកសរុបការពិភាក្សាទាំងនោះ ដោយប្រុងប្រយ័ត្ន ព្រោះវាជាការពិត ហេតុការណ៍ពិសេស ដែលអ្នកគួរតែផ្សព្វផ្សាយទៅខាងក្រៅតាមរយៈ ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកដឹកនាំរបស់សហគមន៍។ ត្រូវបង្កើតនូវព្រឹត្តិការណ៍ឱ្យបានច្រើន ដើម្បីជំរុញក្រុមឱ្យសិក្សាដោយខ្លួនឯង ដើម្បីឈានទៅអនុវត្តមេរៀនផ្សេងៗទៀត។ ត្រូវធ្វើ ទំនាក់ទំនងក្រុមរបស់អ្នកដើម្បីរៀបចំឱ្យមានការ ពិភាក្សា។ សកម្មភាពនាំឱ្យពួកគេយល់ដឹង និងចូលរួមធ្វើសកម្មភាពពិភាក្សាយ៉ាងពេញលេញ ត្រូវចងចាំថាការអនុវត្តមេរៀនទាំងនោះ នៅក្នុងសាលារៀននឹងធ្វើឱ្យសិស្ស និងគ្រូមានការភ្ញាក់ផ្អើល និងចាប់អារម្មណ៍ខ្លាំង។

ការបង្រៀនទាំងនេះ គឺជាសកម្មភាពដ៏ល្អប្រសើរ ហើយជាការបង្រៀនមួយ ដែលអ្នកត្រូវតែធ្វើតាម តែអ្នកអាចធ្វើបានត្រូវចងចាំថា ចែករង្វាន់ដល់អ្នកឈ្នះគេ អាចនាំ ឱ្យមានការចូលរួមពិភាក្សាកាន់តែមានចំនួនច្រើនឡើង។ ប្រហែលជាក្រុមមួយក្នុងចំណោម ក្រុមទាំងអស់អាចទទួលរង្វាន់ពីអាជីវករតាមតំបន់។ ដូចនេះអាជីវករត្រូវតែទទួលព័ត៌មាន អំពីគម្រោងនោះ ព្រមទាំងគំនិតជំទាស់ចំពោះគម្រោងនោះ។

## សកម្មភាព ៤

*ការពិភាក្សាជាក្រុមធំបង្រៀន មួយពេល ឬពីរពេលជាប់គ្នា*



ភាពប្លែកៗនៃអត្ថបទសម្រាប់ពិភាក្សាគឺជា"ការពិភាក្សាជាក្រុម" ដែលនៅក្នុង នោះមនុស្សមួយក្រុមត្រូវបានគេអញ្ជើញឱ្យអង្គុយនៅលើវេទិកា និងការឆ្លើយតបចំពោះ សំណួរពីគណៈអធិបតី ហើយពេលខ្លះទទួលការឆ្លើយតបពីអ្នកស្តាប់ល្អៗ ។

ការពិភាក្សាជាក្រុម : គឺតម្រូវឱ្យមានការរួមគ្នាស្តាប់ ដូចមើលទូរទស្សន៍ និង ស្តាប់វិទ្យុដែរ។ ពួកគេអាចមានការចាប់អារម្មណ៍ខ្លាំង នៅពេលដែលពួកគេអញ្ជើញ ភ្ញៀវពីសហគមន៍ឱ្យទៅចូលរួមក្នុងសកម្មភាពទាំងនោះ។ សកម្មភាពទាំងនេះអាច ទទួលបាននូវអត្ថប្រយោជន៍ សម្រាប់សហគមន៍ និងធ្វើឱ្យមានការចាប់អារម្មណ៍ ទៅលើ ការផ្សាយព័ត៌មាន។ ការពិភាក្សានូវអត្ថបទខ្លីៗគួរតែផុសចេញពីគំនិតណាមួយ នៅក្នុង ពេលប្រជុំក្រុមរបស់អ្នក ហើយការធ្វើការពិភាក្សាជាច់ដោយឡែកអាចនាំមក នូវ របៀបអញ្ជើញភ្ញៀវពីសហគមន៍ឱ្យចូលរួមធ្វើការសកម្មភាព។

ការពិភាក្សាអាចមានប្រយោជន៍ខ្លាំង ធ្វើឱ្យមានការចូលរួមពីសហគមន៍ និងប្រព័ន្ធផ្សព្វផ្សាយ។ ប្រធានបទនៃការពិភាក្សាដោយឡែក អាចនាំមកនូវរបៀបអញ្ជើញភ្ញៀវពីសហគមន៍ ឱ្យចូលរួមធ្វើសកម្មភាពការពិភាក្សា អាចមានប្រយោជន៍ ខ្លាំងធ្វើឱ្យមានការចូលរួមពីសហគមន៍ និងពីប្រព័ន្ធផ្សព្វផ្សាយ។

ប្រធានបទនៃការពិភាក្សាត្រូវដៅចេញពីគំនិតរបស់ក្រុមទាំងមូល អ្នកគួរមានការពិភាក្សាដោយឡែកជាមួយក្រុមរបស់អ្នកជាមុនសិន ដើម្បីស្ទាបស្ទង់ថាអ្នកណាដែលត្រូវអញ្ជើញ ពីសហគមន៍ឱ្យអង្គុយនៅឯវេទិកា។ អ្នកត្រូវចាំថា បុគ្គលដែលអ្នកអញ្ជើញនោះ ត្រូវតែយល់ដឹងប្រធានបទ ដែលស្ដែងចេញមកពីទស្សនៈវិស័យផ្សេងៗហើយចេះលើកឡើងនូវគំនិតជំទាស់ក្នុងការពិភាក្សា។ សកម្មភាពនេះនឹងញ៉ាំងឱ្យអ្នកស្ដាប់ មានការចាប់អារម្មណ៍ខ្លាំងទៅលើការពិភាក្សា ហើយជួយក្រុមឱ្យមានការយល់ដឹងកាន់តែខ្លាំងនូវទស្សនៈវិស័យផ្សេងៗ ដែលសហគមន៍មាននៅក្នុងបញ្ហាផ្សេងទៀត។ មានក្រុមពិភាក្សាក្រុម ជាគន្លឹះនៅក្នុងសហគមន៍ ដែលអាចចូលរួម ពិភាក្សា ហើយមានឈ្មោះថា ជនបង្គោល ៣ភាគី(tripartite stake holders) ក្នុងនោះមាន ILO និយោជិត និយោជក នូវភាគីក្នុងសង្គម (និយោជកសហគមន៍ជំនួញ) មានបំណងចង់បង្កើតឱ្យមានការ ប្រជុំធំ ដើម្បីធ្វើឱ្យមានការចាប់អារម្មណ៍ខ្លាំង។ ជាក់ស្ដែងអ្នកត្រូវទាក់ទងជាមុន ជាមួយសហគមន៍ជំនួញ ក្នុងមូលដ្ឋានដើម្បីស្នើឱ្យគេ ចូលរួមជួយការប្រជុំពិភាក្សា។ អ្នកគប្បីទាក់ទង ជាមួយនិយោ-ជក រដ្ឋាភិបាលថ្នាក់ជាតិ ឬថ្នាក់តំបន់សម្រាប់មេរៀនដំបូងណាមួយ។ អ្នកគប្បីទាក់ទងជាមួយពួកជាមុនដើម្បីឱ្យគេជួយសកម្មភាពពិតនៅពេលក្រោយ។ ការហាត់ហ្វឹកហ្វឺនទាំងនេះនឹងពង្រឹងការទំនាក់ទំនង និងពង្រឹងការចូលរួម របស់សហគមន៍។

ដូចមុនអញ្ចឹងការពិភាក្សាជាក្រុមតម្រូវឱ្យមានការរៀបចំជាមុន ហើយបុគ្គលដែលនៅក្រៅក្រុម គប្បីត្រូវបានទាក់ទង ឬអញ្ជើញឱ្យចូលរួម។ បុគ្គលទាំងនោះត្រូវទទួលដំណឹងឱ្យបានសព្វគ្រប់ អំពីប្រធានបទពិភាក្សា ហើយនិងប្រភេទនៃបញ្ហាត្រូវលើកឡើង ដោយគណៈអធិបតី នៃអង្គប្រជុំ ក្នុងពេលប្រជុំ។




ការប្រជុំពេញអង្គនេះ ត្រូវមានការចូលរួមពីអ្នកទាំងឡាយណា ដែលពាក់ព័ន្ធនឹងបញ្ហា ឬគម្រោងផង។

ការប្រជុំពេញអ្នកដែលល្អ គឺត្រូវមានការដឹកនាំច្បាស់លាស់ ដូច្នេះអ្នកគប្បីចំណាយពេលវេលាខ្លះ ដើម្បីជ្រើសអ្នកណាធ្វើជាអ្នកដឹកនាំ។ អ្នកដឹកនាំអាចជ្រើសរើស ក្នុងចំណោមអ្នកដែលយើងបានអញ្ជើញ មកដូចជានាយកសាលាក្នុងប្រព័ន្ធ អ្នកល្បីឈ្មោះគ្រូបង្រៀន ឪពុកម្តាយ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយប្រធានបទ ត្រូវតែពន្យល់ឱ្យអង្គប្រជុំបានយល់ច្បាស់លាស់មុនការពិភាក្សា។

តួនាទីអ្នកដឹកនាំ គឺត្រូវរក្សាការពិភាក្សា ឱ្យមានដំណើររលូនជានិច្ច។ នៅពេលសមាជិកអង្គប្រជុំបង្ហាញនូវអនុសាសន៍ផ្ទាល់របស់គេ ឬការសន្និដ្ឋានរបស់គេ អ្នកដឹកនាំការប្រជុំគប្បីសួរ ដល់បុគ្គលទាំងឡាយថា តើមានការខ្វែងគំនិតគ្នាក្នុងការសន្និដ្ឋាន ឬក្នុងការទទួលព័ត៌មាន កើតមាននៅឯណា។

សមាជិកអង្គប្រជុំមិនត្រូវលាក់គំនិតជំទាស់របស់ខ្លួនទេម្នាក់ៗ ត្រូវតែបញ្ចេញគំនិត នោះឱ្យដឹងដើម្បីពិភាក្សា។ អ្នកដឹកនាំការប្រជុំត្រូវតែរៀបចំយុទ្ធសាស្ត្រ និងសំណួរបំផុស មួយចំនួនដើម្បីដឹកនាំការពិភាក្សាឱ្យរលូនកុំឱ្យដាច់ ។

អ្នកដឹកនាំត្រូវតែសម្រេចចិត្តបើកការប្រជុំពិភាក្សា ដើម្បីទទួលសំណួរពីអ្នកស្តាប់ ប្រសិនបើអ្នកស្តាប់មិនឯកភាពលើរឿងអ្វីមួយ។ ការធ្វើលំហាត់ហ្វឹកហ្វឺន ត្រូវបើកទូលាយអញ្ជើញឱ្យសហគមន៍ចូលរួម។ សកម្មភាព គឺជាយុទ្ធនាការលើកកំពស់នៃការយល់ដឹង និងលើកកំពស់ភាពសប្បាយរីករាយដែលអាចពង្រឹងសាមគ្គីភាព និងភាពរឹងមាំរបស់គម្រោង រៀបចំឡើងដោយក្រុម។

អាស្រ័យដោយសមាជិកពិភាក្សាពេញអង្គ អ្នកអាចយល់ឃើញថា ប្រព័ន្ធផ្សព្វផ្សាយនៅតាមមូលដ្ឋាន មានការចាប់អារម្មណ៍ខ្លាំងទៅលើសកម្មភាព ហើយប្រព័ន្ធផ្សព្វផ្សាយ នឹងពង្រឹងរបៀប ឬវិធីដឹកនាំសហគមន៍ឱ្យចូលរួមកាន់តែខ្លាំង។ គន្លឹះនៃជ័យជំនះចំពោះការប្រជុំពេញអង្គ គឺអ្នកដឹកនាំអង្គពិភាក្សា។ ការបញ្ចុះបញ្ចូលឱ្យពាណិជ្ជករ ឬអ្នកគ្រប់គ្រងហាងទំនិញឱ្យចូលរួមការពិភាក្សាស្តីពីពលកម្មកុមារនោះ មិនមែនការលំបាកឡើយ ក៏ប៉ុន្តែដើម្បីជំរុញ ឱ្យមានការចាប់អារម្មណ៍ ហើយបើកបរិយាកាសទូលាយដល់អ្នកស្តាប់ និងបញ្ចេញផ្សព្វផ្សាយអ្នកដឹកនាំ

ការពិភាក្សា ត្រូវតែជាអ្នកមានសមត្ថភាពអាចដឹកនាំក្រុមឱ្យនិយាយ មិនស្ងៀមស្ងាត់ ហើយចេះផ្សារភ្ជាប់រវាងអនុសាសន៍ផ្សេងទៀត។ អ្នកដឹកនាំការពិភាក្សា គឺត្រូវចេះដឹងអំពីរបៀបដឹកនាំការពិភាក្សា។ អ្នកដឹកនាំត្រូវចេះសង្ខេប ការពិភាក្សា ហើយចេះដកស្រង់យកចំណុចសំខាន់ៗនៃការពិភាក្សា ព្រោះការពិភាក្សាអាចជះឥទ្ធិពលខ្លាំងទៅលើសហគមន៍។ យើងត្រូវដឹងឱ្យច្បាស់ថា ក្រុមរបស់អ្នកបានចូលជ្រៅ ទៅក្នុងការពិភាក្សាហើយ ឬនៅ? ជាការប្រសើរ ប្រសិនបើសមាជិក បានស្ថិតនៅលើវេទិកាពិភាក្សាជាមួយភ្ញៀវដែលត្រូវគេអញ្ជើញមក។

## អ្វីដែលអ្នកត្រូវធ្វើ និងមិនត្រូវធ្វើ



- ត្រូវដឹងឱ្យច្បាស់ថា បុគ្គលនីមួយៗ ប្រាកដជាបានចូលរួមដល់ការបង្រៀន នៃម៉ូឌុលនេះ។ ត្រូវជួយអ្នកណាដែលខ្វះសេចក្តីទុកចិត្ត ក្នុងការសិក្សាស្រាវជ្រាវ និងខ្វះសមត្ថភាពក្នុងការសរសេរ ហើយជួយអ្នកណា ដែលត្រូវបានសន្ទាប់ដោយសាធារណជនក្នុងការហាត់ហ្វឹកហ្វឺននេះ។
- ត្រូវព្យាយាមយល់ឱ្យច្បាស់ថា បុគ្គលខ្លះ ប្រាកដជាមិនរក្សាគំនិតនៅកណ្តាលទេ។ ឧទាហរណ៍ "មិនបានធ្វើការសម្រេច ចិត្ត" ក្នុងការផ្លាស់ប្តូរលំហាត់ពិភាក្សា។ ប្រសិនបើអ្នកកំណត់សំគាល់ថា បុគ្គលទាំងនោះតែងតែស្ថិតនៅជាអព្យាក្រិត្យ "អ្នកត្រូវសន្មតថា អ្នកទាំងនោះបានទទួលមីក្រូ ហើយស្នើឱ្យពន្យល់អំពីមូល-ហេតុ។
- បន្ទាប់មកអ្នកដទៃទៀតបានថ្លែងពីគោលជំហររបស់គេមកអ្នកត្រូវសួរអ្នកអព្យាក្រិត្យដែលនៅកណ្តាលដោយផ្ទាល់តែម្តង ប្រសិនបើពួកគេចង់ផ្លាស់កន្លែងទៅកាន់ ក្រុមផ្សេងទៀត។ ពួកគាត់អាចឆ្លើយប្រាប់មូលហេតុ។
- ត្រូវដឹងឱ្យច្បាស់ថា អ្នកគ្រប់គ្នានៅក្នុងក្រុមប្រាកដជាមានឱកាស ចាប់យកមីក្រូ ហើយនិយាយបង្ហាញចំណុចសំខាន់ៗរបស់គេ។ ក្រុមនីមួយៗនឹងមានបុគ្គល ដែលអាចសំដែងបញ្ចេញមតិជាសាធារណៈបានងាយស្រួលជាងអ្នកដទៃ។ ប៉ុន្តែត្រូវធានាកុំឱ្យពួកគេគ្របសង្កត់ ឬរំលោភទៅលើការពិភាក្សា។ ត្រូវធានាថា វិន័យរបស់មីក្រូទិព្វ ត្រូវតែបានគោរពឱ្យបានត្រឹមត្រូវដាច់ខាត។ កាលណាអ្នកកាន់មីក្រូទិព្វនិយាយ អ្នកដទៃត្រូវតែស្តាប់ដោយស្ងប់ស្ងៀម។

ត្រូវបញ្ចូលការសប្បាយរីករាយទៅក្នុងក្រុមពិភាក្សា ដើម្បីញ៉ាំងការពិភាក្សា ឱ្យស្ថិតនៅបានយូរ ។

- ម៉ូឌុលដែលនាំឱ្យមានការសប្បាយរីករាយ អាចពង្រឹងស្មារតី និងការចូលរួមយ៉ាងខ្លាំងក្លាផងដែរ ។ យុវជន មិនដឹងថា ពួកគេបានចេះច្រើនប៉ុនណាទេ រហូតដល់ពួកគេអាចប្រើប្រាស់សម្ភារទាំងនេះនៅក្នុងម៉ូឌុលផ្សេងៗ នៅក្នុងឆាកជីវិតនៅតាមតំបន់ផ្សេងៗ និងនៅក្នុងការអប់រំរបស់ពួកគេទាំងនោះឡើយ ។
- មិនត្រូវអនុញ្ញាតឱ្យធ្វើការតិតៀន ឬប្រើភាសាមិនល្អក្នុងពេលប្រជុំ ព្រោះវានឹងដឹកនាំឱ្យមានការជំទាស់ និងការបែកបាក់នៅក្នុងក្រុមមួយ ដែលធ្លាប់តែស្វាហាប់ ។



- មិនអនុញ្ញាតឱ្យក្រុមធ្វើការសើចសប្បាយរីករាយ ប៉ះពាល់ដល់បុគ្គលដែលមានគោលជំហរពិសេសតែម្នាក់ឯងគត់ក្នុងការសិក្សា ។ មូលដ្ឋានតម្លៃនៃការគោរពគ្នាទៅវិញទៅមក និងសេចក្តីគោរពសម្រាប់សិទ្ធិសេរីភាព នៃបុគ្គលម្នាក់ៗត្រូវបានពង្រឹងតាមរយៈម៉ូឌុលទាំងនេះ ។ គំនិតរបស់បុគ្គលម្នាក់ៗ ត្រូវតែបានគោរព និង ត្រូវបានគេយកចិត្តទុកដាក់ ។
- ត្រូវយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លា ចំពោះក្រុមដែលសកម្ម និងស្វាហាប់ និងចំពោះការប្រតិកម្ម របស់បុគ្គលម្នាក់ៗក្នុងការហាត់ហ្វឹកហ្វឺន ។ ប្រសិនបើសមាជិកនីមួយៗនៃក្រុមទាំងនោះ មានអារម្មណ៍ស្រួល ជាមួយការពិភាក្សាពិសេសណា ជាមួយគំនិតដែលស្តែងចេញមក ឬពួកមិនអាចចូលរួមក្នុងការធ្វើលំហាត់ អ្នកត្រូវតែយល់ដឹងនឹងយកចិត្តទុកដាក់ចំពោះអារម្មណ៍របស់គេ ។ អ្នកត្រូវតែព្យាយាមបញ្ចូលអារម្មណ៍របស់ពួកគេទៅក្នុងការពិភាក្សាឱ្យអស់លទ្ធភាពដែលមាន ។
- ចូរអ្នកកុំខ្លាច ត្រូវហ៊ានបញ្ឈប់ការពិភាក្សាពិសេសណាមួយ ប្រសិនបើអ្នកយល់ថា មិនអាចគ្រប់គ្រងបាន ហើយអាចនាំឱ្យមានបញ្ហាដល់ក្រុមពិភាក្សាពិសេស នៅពេលប្តូរកន្លែងអង្គុយពិភាក្សា ។ ប៉ុន្តែទោះបីយ៉ាងណា ក៏ដោយរឿងដែលបុគ្គលនីមួយៗអាចសំដែងចេញមកនូវអ្វីដែលគេយល់ឃើញថាខ្លាំង ហើយល្អ ។ ការបញ្ឈប់ការពិភាក្សាដែលនាំឱ្យមានបញ្ហា គឺជាមធ្យោបាយចុងក្រោយបំផុតប្រសិនបើមិនអាចគ្រប់គ្រងវាបាន ។

- អ្នកត្រូវតែមានសេចក្តីប្រាថ្នាច្រើនសម្រាប់ក្រុម និងលើកទឹកចិត្តក្រុម ឱ្យមានសេចក្តីប្រាថ្នាច្រើនផងដែរ បន្ទាប់មកត្រូវណែនាំពួកគេឱ្យពិភាក្សាជ្រើសរើសមនុស្សដែលត្រូវអញ្ជើញឱ្យមកពិភាក្សាបញ្ចេញមតិជំទាស់ ហើយជួយពួកគេ ក្នុងការរៀបចំ ការអញ្ជើញ និងជួយសម្រួលការងារផ្សេងៗទៀតផង។
- ត្រូវទាញយកអត្ថប្រយោជន៍ឱ្យបានពេញលេញពីឱកាសផ្សេងៗដើម្បីពង្រឹងឥទ្ធិពលនៃចំណេះដឹងឱ្យបានខ្លាំងក្លា និងដើម្បីដឹងឱ្យច្បាស់ថា ក្រុមប្រាកដជាមានការជឿជាក់ ហើយរួមចំណែកក្នុងការខិតខំប្រឹងប្រែងនេះ។
- ត្រូវប្រើប្រាស់កាមេរ៉ា វីដេអូ ប្រសិនបើមានលទ្ធភាព ដើម្បីថតសម័យប្រជុំពិភាក្សាទាំងនោះ។ ការប្រើប្រាស់នេះអាចធ្វើឡើងច្រើនរបៀប។ គេអាចប្រើប្រាស់ជាឧបករណ៍សម្រាប់លើកកំពស់ ការយល់ដឹងជាមួយក្រុមដទៃទៀត ហើយពួកគេអាចប្រើប្រាស់ វាជាសម្ភារគរុកោសល្យ ក្នុងការជួយក្រុមឱ្យមានការរីកចំរើន ក្នុងការថ្លែងមតិជាសាធារណៈ និងញ៉ាំងបច្ចេកទេសពិភាក្សាឱ្យកាន់តែល្អ ដ៏ពិសេសថែមទៀត។
- ត្រូវរៀបចំវេទិកាពិភាក្សា ប្រសិនបើអ្នកយល់ថា ក្រុមអាចគ្រប់គ្រងវាបាន។ វេទិកានេះ ជំរុញឱ្យមានការពាក់ព័ន្ធនឹងការចូលរួមពីសហគមន៍ ហើយវេទិកាអាចធ្វើឱ្យអ្នកចូលរួមស្តាប់មានការចូលចិត្តយ៉ាងខ្លាំង។
- ត្រូវប្រើប្រាស់វេទិកានេះ ដើម្បីឱ្យក្រុមមានឱកាសសំដែងដោយសេរី ដោយគ្មានការបង្ខំ។ ត្រូវឱ្យក្រុមឈប់សម្រាក ដើម្បីទស្សនារូបខ្លួនឯង ស្តាប់សំលេងខ្លួនឯង ហើយសប្បាយពីរូបខ្លួនឯង។ បើមានថតជាវីដេអូ ហើយចម្រាញ់យកមេរៀន និងចំណេះល្អៗតាមរយៈខ្សែវីដេអូនេះ។ ត្រូវរក្សាសុន្ទរកថាថ្លែង មតិដែលក្រុមផលិតបានឱ្យគង់វង្សទាំងអស់។

## ការពិភាក្សាបញ្ចប់

*បង្រៀន ១ពេល*

ការពិភាក្សាគឺជាកំលាំង ដែលអាចលើកកំពស់បទពិសោធន៍ ឱ្យកាន់តែប្រសើរ អ្នកខ្លះក្នុងក្រុមពិភាក្សារបស់អ្នកមិនទាន់បានឆ្លងកាត់ការហ៊ឹកហ្វឺនពីមុនឡើយ ។ ហើយពួកគេត្រូវការការគាំទ្រខ្លះៗ ហើយក៏ស្ថិតនៅស្ងៀម ហាក់ដូចជាពួកគេបានដល់ទីបញ្ចប់នៃលំហាត់ហើយ ។ ដូច្នេះត្រូវការបង្កើតនូវបរិស្ថានស្ងប់ស្ងាត់ និងបណ្តោយឱ្យពួកគេជជែកគ្នាបញ្ចេញការរំជួលចិត្តព្រមទាំងឱ្យពួកគេបរិយាយលំអិតនូវអ្វីដែលពួកគេបានឆ្លងកាត់ ។ ត្រូវពិភាក្សាលំអិតអំពីការសន្ទនាទាំងនោះ ។ ត្រូវបើកវេទិកាប្រជុំសម្រាប់សមាជិក ក្នុងក្រុមហើយលើកទឹកចិត្តដល់ពួកគេឱ្យសួរគ្នាទៅវិញទៅមក ។ រឿងដែលសំខាន់ គឺដឹងមូលហេតុដែលបុគ្គលនីមួយៗ ជជែកការពារអ្វីដែលគេបានធ្វើ និងរបៀបដែលគេនិយាយទៅកាន់អ្នកស្តាប់ ។ការពិភាក្សានិងការថ្លែងសុន្ទរកថាខ្លះ ហាក់ដូចជាមានគុណភាពខ្ពស់ ហើយអ្នកគ្រប់គ្នាមានការផ្ចង់ស្មារតី ចំពោះការថ្លែងសុន្ទរកថាទាំងនោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ជាការប្រសើរត្រូវពិនិត្យជាមុន ដើម្បីរក្សាតម្លៃរបស់វា ។

ត្រូវនិយាយទៅកាន់ក្រុម ស្តីអំពីការចូលរួមពីអ្នកស្តាប់ ជាពិសេសមកលើប្រព័ន្ធផ្សព្វផ្សាយ និងពិភាក្សាស្វែងរករបៀបអនុវត្តបន្តពីម៉ូឌុល ដែលបានរៀនពីម៉ូឌុលដែលមានចំណងជើង ថា "ប្រព័ន្ធផ្សព្វផ្សាយ" "Media Modules"។ ប្រសិនបើអ្នកមិនទាន់បានអនុវត្តម៉ូឌុល "Media Modules" នោះទេ ម៉ូឌុលនោះនឹងមាននៅលើតារាងណែនាំ ស្តីពីការទាក់ទងជាមួយប្រព័ន្ធផ្សព្វផ្សាយ ។

ប្រសិនបើអ្នកបានថតវីដេអូ ស្តីពីការពិភាក្សា សូមបង្ហាញវីដេអូនេះដល់ជាក្រុម ។ វីដេអូនេះនឹងផ្តល់ការសប្បាយរីករាយ ដល់ពួកយុវជន នៅពេលពួកគេនៅក្នុងវីដេអូ ។ ប៉ុន្តែវីដេអូនេះនឹងជួយ



### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

មេរៀនទាំងនេះត្រូវបានគេប្រើប្រាស់កាន់តែច្រើនឡើងៗ IPECមានការ ភ្ញាក់រលឹកថា និងមានប្រភពប្រកប ដោយសក្តានុពលដ៏ធំធេងមួយនៃសម្ភារសម្រាប់បង្កើតទិន្នន័យនៃប្រធានបទ ឬស្ថានភាពផ្សេងៗទៀត សំរាប់មេរៀនទាំងនោះ ។ ដូច្នេះយើងធ្វើការលើកទឹកចិត្តដល់អ្នកអប់រំដែលប្រើប្រាស់មេរៀនទាំងនេះ ដើម្បីផ្ញើទៅIPECនូវចំណងជើងប្លែកៗនៃប្រធានបទខុសៗគ្នា ដែលក្រុមរបស់គេ បានគិតឃើញ ហើយបានចងក្រង ឧទាហរណ៍បង្កើតឡើងជាបញ្ជីសម្រាប់ឱ្យ អ្នកដទៃទៀតយកទៅប្រើប្រាស់ ។

សុន្ទរកថាថតចំលងសម្រាប់ធ្វើជាសម្ភារប្រើប្រាស់ត្រូវបានធ្វើឡើងដោយមាន ការថតវីដេអូផង ។



បង្ហាត់បង្រៀនពួកគេ ក្នុងពេលពិភាក្សា ក្នុងពេលនិយាយ ជាសាធារណៈ និងជំនាញខាងសំដែងរឿងល្ខោន។ ដោយផ្តោតទៅលើបច្ចេកទេស និងរបៀបនិយាយជាសាធារណៈ ខ្លួនអ្នក និងអ្នកគាំទ្រពីក្រៅរបស់អ្នកអាចធ្វើការដើម្បីលើកកំពស់គុណភាពបុគ្គល និងសង្គម។ គុណភាពនេះនឹងស្ថិតនៅជាមួយជីវភាពរបស់យុវជនជានិច្ចនៅពេលអនាគត។

## ការវាយតម្លៃ និងសកម្មភាពបន្ត



គិតតាមអាំងឌីកាទ័រសម្រាប់ម៉ូឌុលទាំងនេះយើងមានលទ្ធផលជាក់ស្តែង ដែលអាចកើតមាន ឬមិនអាច។ យ៉ាងហោចណាស់អ្នកខ្លះ នៅក្នុងក្រុមរបស់អ្នក បានធ្វើការស្រាវជ្រាវសរសេរសុន្ទរកថា ស្របតាមបរិបទនៃការពិភាក្សា ស្តីពីពលកម្មកុមារ។ គុណភាពនៃការងារនេះផ្អែកទៅលើបុគ្គល ដែលពាក់ព័ន្ធ ក៏ប៉ុន្តែគុណភាពអាស្រ័យដោយម៉ូឌុលនេះ ឬម៉ូឌុលផ្សេងទៀតដែលត្រូវបានអនុវត្តបានល្អដល់កម្រិតណាផងដែរ។

ម៉ូឌុលនេះរៀបចំឡើង សម្រាប់លើកកំពស់ការយល់ដឹង ឱ្យបានប្រសើរឡើងជាលំដាប់ក្នុងចំណោមយុវជន ហើយជំរុញឱ្យឆ្លើយតប ដោយក្តីរំភើប ចំពោះពលករកុមារ ដើម្បីឱ្យពួកគេជួយឧបត្ថម្ភយុទ្ធនាការលុបបំបាត់ពលកម្មកុមារ។

ឆ្លងតាមបច្ចេកទេសពិភាក្សា យើងកំពុងតែឈានទៅរកកម្រិតថ្មីនៃការយល់ដឹង និងការឆ្លើយតប។ សកម្មភាពនេះគឺជាកំលាំងថាមពលមួយ ដែលអាចមានឥទ្ធិពលទៅលើយុវជន។ ការពិភាក្សា និងការនិយាយជាសាធារណៈ ធ្វើឱ្យយុវជន មានកំលាំងថាមពលកាន់តែខ្លាំងឡើង។ ពិសេសចំពោះអ្នកស្តាប់ ដែលក្នុងនោះ មានអាយុប្រហាក់ប្រហែលគ្នា អ្នកដឹកនាំសហគមន៍ និងបណ្តាញផ្សព្វផ្សាយការងារនេះ ត្រូវផ្អែកលើការប៉ិនប្រសប់របស់បុគ្គលផងដែរ។ នៅពេលនិយាយជាសាធារណៈ ពួកគេស្ថិតនៅក្នុងដំណាក់កាលមួយ ចំពោះមុខអ្នកស្តាប់ ទាំងឡាយបានសេចក្តីថា នេះគឺការហាត់សំដែងរឿងមួយ។ អ្នកទាំងឡាយណា ដែលធ្វើលំហាត់បានល្អ អ្នកទាំងនោះនឹងក្លាយទៅជាអ្នកគាំទ្រដ៏មានប្រសិទ្ធភាព ចំពោះយុទ្ធនាការលុបបំបាត់ពលកម្មកុមារ។

នៅពេលដែលអ្នកបានបញ្ចប់ម៉ូឌុលនេះអ្នកត្រូវឈាន ទៅរកម៉ូឌុលថ្មី

ទៀត។ យើងសូមបញ្ជាក់ថាបន្ទាប់ពីនេះ អ្នកត្រូវសរសេរអត្ថបទផ្សព្វផ្សាយតាមសារព័ត៌មាន តាមវិទ្យុ តាមទូរទស្សន៍ ការសំដែងសិល្បៈ ជាល្ខោន ឬការដើរតួ។

## ឧបសម្ព័ន្ធ ១

-ជំនាញពិភាក្សាជាមូលដ្ឋាន

-កំណត់សម្គាល់សម្រាប់អ្នកអប់រំ និងអ្នកពិភាក្សា

### ការពិភាក្សា

ការពិភាក្សាជាមូលដ្ឋាន ជាការពិគ្រោះយោបល់ និងបង្ហាញអំណះអំណាងជំទាស់នេះ មិនមែនមានន័យថា គឺជាការស្រែកឡូឡាឥតសណ្ដាប់ធ្នាប់ ប្រកួតប្រជែងគ្នាទៅតាមអំពើចិត្តនោះទេ។ ការជំទាស់ប្រាកដជាមាននៅក្នុងការពិភាក្សា។ ការពិភាក្សាមានវិន័យតឹងរ៉ឹងរបស់វា ដែលនាំទៅរកការជំទាស់ប្រកប ដោយបច្ចេកទេស។ បុគ្គលនីមួយៗរកឃើញមតិជំទាស់នៅក្នុងស្ថានភាពមួយ ដែលនៅក្នុងនោះពួកត្រូវតែគាំទ្រការជំទាស់។

ប្រសិនបើការពិភាក្សា ជាទម្រង់នៃការផ្ដល់អំណះអំណាងជំទាស់ ដែលសមហេតុសមផល សូមឱ្យការពិភាក្សានោះមានដំណើរការទៅមុខចុះ។ ជួនកាលអំណះអំណាងជំទាស់នោះ ជាបញ្ហាថ្មីៗពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ ឬពាក់ព័ន្ធនឹងទស្សនៈវិជ្ជា ឬគំនិតយោបល់ទូទៅ។ រាល់ប្រធានបទ ត្រូវចាប់ផ្ដើមដោយពាក្យ "នោះ" (That) ឧទាហរណ៍ដូចជាប្រធានបទពិភាក្សាស្ដីពី ពលកម្មកុមារ គប្បីសរសេរថា "កុមារទាំងនោះត្រូវទៅរៀន មិនត្រូវធ្វើការទេ (that children....)។ ដូចនៅក្នុងអំណះអំណាងផ្សេងទៀត ប្រធានបទនីមួយៗតែងតែមានមុខពីរ (ឬជ្រុងពីរ)។ ក្រុមដែលស្របនឹងប្រធានបទមានឈ្មោះថា ក្រុមស្រប (ឬក្រុមរដ្ឋាភិបាល) នៅក្នុងការពិភាក្សារបស់ក្រុម។ រីឯក្រុមដែលមិនយល់ស្របមានឈ្មោះថា ក្រុមជំទាស់ក្នុងការពិភាក្សារបស់សភា។ នៅពេលរៀបចំការពិភាក្សា ការសំខាន់គឺត្រូវជ្រើសរើសយកប្រធានបទ ស្របទៅតាមអាយុអប់រំ របស់អ្នកចូលរួមពិភាក្សា ដែលពាក់ព័ន្ធ។នៅក្នុងករណីធ្វើគម្រោង (ប្រធានបទត្រូវគ្របដណ្ដប់លើតំបន់ដែលអ្នកពិភាក្សារស់នៅ ហើយមានការចាប់អារម្មណ៍។

### និយមន័យ

ប្រសិនបើការពិភាក្សាកំពុងតែមានដំណើរការ យើងត្រូវតែយល់ព្រមឱ្យការពិភាក្សាមានដំណើរការទៅមុខ។ ដូច្នេះយើងត្រូវតែឯកភាពស្របទៅនឹងអត្ថន័យរបស់ប្រធានបទនោះ។ ការសម្រេចចិត្ត និងការពន្យល់អត្ថន័យ របស់ប្រធានបទយើងឱ្យឈ្មោះថា "ការកំណត់និយមន័យរបស់ប្រធានបទ"

ការកំណត់និយមន័យ ចាប់ផ្ដើមឡើង ដោយមានការឯកភាពស្របជាមួយក្រុម។ អ្នកសំដែងមតិស្របមុនគេបង្អស់ គប្បីបន្យល់ដោយ ប្រើពាក្យពេចន៍ច្បាស់លាស់ ថាពួកគេជឿជាក់ទៅលើអត្ថន័យ របស់ប្រធានបទ។ នៅពេលសម្រេចចិត្តកំណត់ យកនិយមន័យ ដូចនេះក្រុមស្របព្យាយាមប្រើប្រាស់ "មនុស្ស ដែលគេធ្វើតែស្ដនៅតាមថ្នល់"។

ប្រសិនបើប្រធានបទនេះ ត្រូវបានគេបង្ហាញដល់មនុស្សមួយចំនួននៅតាមដងផ្លូវ ដើម្បីធ្វើតែស្តទៅលើនិយមន័យនេះ ក្រុមមិនឯកភាព អាចយល់ព្រម ឬជំទាស់នឹង និយមន័យដែលត្រូវបាន គេលើកមកបង្ហាញ។

ក្រុមជំទាស់ត្រូវតែប្រុងប្រយ័ត្នជានិច្ចក្នុងការសំដែង មតិជំទាស់ ពីព្រោះវាអាចនាំ ឱ្យមានការលំបាកក្នុងការធ្វើការពិភាក្សា ដោយផ្អែកលើនិយមន័យពីរដូចនេះ។ ការជំទាស់គប្បីត្រូវធ្វើ ប្រសិនបើនិយមន័យដែលគេកំណត់ឱ្យនោះមិនសមហេតុផល។ ប្រសិនបើក្រុមបដិសេធរករឿងជំទាស់ទៅលើនិយមន័យ ការជំទាស់គប្បីធ្វើឡើង ដោយអ្នកដែលនិយាយមុនគេ ដោយគូសបញ្ជាក់ឱ្យឃើញច្បាស់នូវមូលហេតុនៃភាពមិនសមស្រប រួចស្នើឱ្យធ្វើការពិភាក្សារកនិយមន័យ ដែលល្អប្រសើរជាងគេ។

ការពិភាក្សាគឺជាហេតុការណ៍ ឬព្រឹត្តិការណ៍របស់ក្រុម ហើយជាធម្មតាតែងតែមានវាគ្មិន ៣នាក់តំណាងឱ្យក្រុមនីមួយៗ។ ជាការសំខាន់ គឺអ្នកនិយាយទាំង៣នាក់នោះ ធ្វើរួមគ្នា ដូចជាក្រុមតែមួយ។ ភារកិច្ចរបស់ក្រុម គឺត្រូវកំណត់ និងពន្យល់ឱ្យច្បាស់ថា ហេតុអ្វីបានជាប្រធានបទមានន័យត្រឹមត្រូវ (សម្រាប់អ្នកគាំទ្រ) ហើយហេតុអ្វីបានជាប្រធានបទមានន័យមិនត្រឹមត្រូវ (សម្រាប់អ្នកជំទាស់)។ ឃ្លាប្រយោគគប្បីខ្លី ហើយត្រូវអាន ឬពោលដោយអ្នកនិយាយទី១ របស់ក្រុមនីមួយៗ រួចត្រូវបានបញ្ជាក់បន្ថែម ដោយអ្នកនិយាយ ពីរនាក់ផ្សេងទៀត ដើម្បីការពារគំនិត របស់ក្រុមការងារ។

**តួនាទីរបស់អ្នកនិយាយ**

នៅក្នុងក្រុមពិភាក្សា អ្នកនិយាយម្នាក់ៗមានតួនាទីច្បាស់លាស់ ដែលពួកគេត្រូវបំពេញ ដើម្បីរួមចំណែកនៅក្នុងក្រុម។ អ្នកនិយាយត្រូវឡើងនិយាយទៅតាមលំដាប់លំដោយ បន្តបន្ទាប់គ្នា តាមវេន របស់ខ្លួន។ គេកំណត់និយមរបស់ប្រធានបទ ត្រូវបង្ហាញនូវគោលគំនិតរបស់ក្រុមគាំទ្រ។ ត្រូវបង្ហាញឱ្យឃើញត្រួសៗនូវអ្វីដែលក្រុមរបស់ត្រូវនិយាយនៅពេលបន្តិចទៀតនេះ។

ត្រូវបង្ហាញមួយផ្អែកពាក់កណ្តាលនៃករណីយល់ស្រប។

អ្នកបដិសេធទីដំបូងគេគួរតែ : ទទួល ឬច្រានចោលនិយមន័យ ប្រសិនបើមិនបដិសេធទេ ត្រូវតែយល់ព្រមទទួលនិយមន័យនោះ) ត្រូវបង្ហាញគោលការណ៍របស់ក្រុមជំទាស់។ ត្រូវបង្ហាញឱ្យឃើញត្រួសៗ នូវអ្វីដែលក្រុមជំទាស់ត្រូវនិយាយនៅពេលបន្តិចទៀតនេះ។ ត្រូវជំទាស់ ឬបដិសេធចំណុចតិចតួច ក្នុងចំណោមចំណុចសំខាន់ៗរបស់អ្នកនិយាយគាំទ្រដំបូងគេ។ អ្នកជំទាស់ដំបូងគេ ត្រូវប្រើពេលវេលាមួយភាគបួន នៃពេលវេលារបស់ខ្លួនដើម្បីបដិសេធចំណុចខ្លះៗនោះ។ ត្រូវបង្ហាញ១ភាគពាក់កណ្តាលនៃករណីជំទាស់ របស់ក្រុម។ ក្រុមទី២ គួរតែ : ពោលអះអាងការពារគោលគំនិតរបស់ក្រុមគាំទ្រ រួចបដិសេធចំណុចខ្លះ ក្នុងចំណោមចំណុចសំខាន់ៗដែលក្រុមជំទាស់លើកឡើង។ ក្រុមគាំទ្រទី២នេះគប្បីចំណាយ ១/៣ នៃពេលវេលារបស់ខ្លួន ដើម្បីបដិសេធ។ ត្រូវបង្ហាញតែ ១ភាគពាក់កណ្តាលនៃករណីរបស់ក្រុមគាំទ្រ។

ក្រុមបដិសេធទី២គួតែ : ប្រកាន់ខ្ជាប់នូវគោលការណ៍បដិសេធត្រូវទាត់ចោលនូវចំណុចសំខាន់ៗខ្លះ របស់ក្រុមគាំទ្រ។ ក្រុមបដិសេធទី២នេះ គួរតែចំណាយ ១/៣នៃពេលប្រហែលរបស់ខ្លួនដើម្បីធ្វើការបដិសេធ។ ត្រូវលើកឡើង ១ភាគពាក់កណ្តាលនៃករណីរបស់ក្រុមបដិសេធ។

ក្រុមយល់ស្របទី៣ គួរតែ : ប្រកាន់ខ្ជាប់នូវគោលការណ៍របស់ក្រុមគាំទ្រ។ ត្រូវទាត់ចោលចំណុចទាំងអស់ ដែលក្រុមជំទាស់លើកឡើង។ ក្រុមយល់ស្របទី៣គួរតែចំណាយ២/៣ ទៅ៣/៤នៃពេលវេលា របសខ្លួនដើម្បីធ្វើការទាត់ចោលរាល់គំនិតអ្នកប្រឆាំង។ ត្រូវលើកឡើងនូវសេចក្តីសង្ខេប នៃករណីរបស់ក្រុមគាំទ្រ ឬក្រុមយល់ស្រប។ ជុំវិញការពិភាក្សាឱ្យស្ថិតនៅជុំវិញគំនិតដែលគាំទ្រ ឬយល់ស្រប។

ក្រុមបដិសេធទី៣ ឬក្រុមជំទាស់ទី៣ គប្បីពោលអះអាងគោលការណ៍របស់ក្រុមជំទាស់ ហើយទាត់ចោលចំណុចទាំងអស់នៃករណីរបស់ក្រុមគាំទ្រ។ ក្រុមជំទាស់ទី៣នេះ គប្បីចំណាយ ២/៣ ឬ៣/៤ នៃពេលវេលារបស់ខ្លួន ដើម្បីធ្វើការទាត់ចោល។ ត្រូវបង្ហាញសេចក្តីសង្ខេបនៃករណីរបស់ក្រុមជំទាស់។ ត្រូវដឹកនាំការពិភាក្សាដើម្បីជំទាស់។

**ជំទាស់ ឬការប្រឆាំង**

ក្នុងការពិភាក្សាក្រុមនីមួយៗរក្សាខ្ជាប់នូវចំណុចសំខាន់ៗរបស់ខ្លួនដើម្បី ជាប្រយោជន៍នៃករណីនៃក្រុមរបស់គេ។ ពួកគេចំណាយពេលវេលា ដើម្បីតិតៀនមតិអំណះអំណាងលើកឡើងដោយក្រុមផ្សេងទៀត។ អំពើនេះមានឈ្មោះ "ការជំទាស់ ឬប្រឆាំង"

- ភាពសមហេតុសមផល គឺជាការនិយាយថា យោបល់ក្រុមម្ខាងផ្សេងទៀតមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់។ អ្នក ពិភាក្សា ត្រូវបង្ហាញ និងពន្យល់ឱ្យច្បាស់ថា ហេតុអ្វីបានជាមតិនៃក្រុមម្ខាងទៀតមិនត្រឹមត្រូវ។
- ការលើកយកចំណុចសំខាន់ៗ នៃអំណះអំណាង របស់ក្រុមផ្សេងទៀតមកបង្ហាញថា មិនមានន័យសមស្របឡើយ។ ធ្វើដូច្នេះទើបការពិភាក្សាមានដំណើរការល្អប្រសើរ។ ពីព្រោះការគិតក្នុងការពិភាក្សានេះ ត្រូវធ្វើឡើងរហ័សណាស់។ ម្ល៉ោះការខ្វះខាតតែងតែមាន។ ការបញ្ចេញមតិនេះ គឺជាប្រឡងប្រណាំង ហើយនាំឱ្យមានការ សប្បាយរីករាយក្នុងការពិភាក្សាផង។

ត្រូវព្យាយាមបដិសេធនូវចំណុចសំខាន់ៗ នៃករណីរបស់ក្រុមម្ខាងទៀត។ ក្រោយមកអ្នកពិភាក្សានឹងសម្គាល់ឃើញថា មានភាពងាយស្រួលកាន់តែខ្លាំងឡើងៗក្នុងការកំណត់ ឬយល់ដឹងអ្វីដែលត្រឹមត្រូវ។ អ្វីដែលជាក់ស្តែងសម្រាប់ពួកគេនោះ គឺអ្វីដែលក្រុមផ្សេងទៀតនឹងលើកឡើង។ ប៉ុន្តែមិនត្រូវកាត់ចោលចំណុចសំខាន់ទាំងអស់នោះរហូតដល់ពេលចុងបញ្ចប់នោះទេ។

- លេងល្បែងដោយប្រើពាក្យផ្សេងទៀត ពាក្យលេងល្បែងមានន័យថា លេងមិនបន្លំលេងត្រឹមត្រូវ មិនតិតៀនបុគ្គល តិតៀនអ្វីដែលបុគ្គលនិយាយលើកឡើង។

អ្នកធ្វើបទអន្តរាគមន៍ មានបច្ចេកទេសច្រើនណាស់ ដែលអ្នកនិយាយម្នាក់អាចប្រើប្រាសក្នុងសុន្ទរកថា សំដែងមតិរបស់គេ ប៉ុន្តែមាន បច្ចេកទេស ៣ផ្នែកសំខាន់ៗ គឺ : បញ្ហា វិធីសាស្ត្រ របៀប ។

- បញ្ហា

ការពិគ្រោះយោបល់មួយ គឺជារបាយការណ៍មួយ : ប្រធានបទ គឺពិតបញ្ហា គឺអ្វីដែលបុគ្គលណាមួយនិយាយលើកឡើង ។ អ្វីនោះគឺជាសាច់រឿងក្នុងសុន្ទរកថា ។ បញ្ហាត្រូវតែចែកចេញ ជាអំណះអំណាង និងជាឧបករណ៍សម្រាប់បញ្ជាក់ ។ អំណះអំណាងគឺជាការសន្និដ្ឋានថា ប្រធានបទត្រឹមត្រូវ ឬ មិនត្រឹមត្រូវ ។ វាអាស្រ័យទៅលើក្រុមដែលអ្នកស្ថិតនៅក្នុងនោះ ។ ឧទាហរណ៍ដូចជា ប្រធានបទស្តីពី "សួនសត្វត្រូវតែបិទព្រោះពួកគេឃុំឃាំងសត្វនៅក្នុងបរិស្ថាន មិនមែនជាធម្មជាតិ ។ នៅពេលពិភាក្សា អាចមានមតិគាំទ្រ អំណះអំណាង "សួនសត្វត្រូវតែបិទ....." ។ នៅក្នុងសួនសត្វ សត្វជាច្រើនមានទីវាលតែ ២០០ ម៉ែត្រការេ តែប៉ុណ្ណោះ ប៉ុន្តែសត្វទាំងឡាយចង់បាន ទីវាលមានទំហំ ២០០០គីឡូម៉ែត្រការេសម្រាប់ដើរ ។

ទោះបីយ៉ាងណាក៏ដោយ "បញ្ហា" មិនអាចនាំឱ្យមានការលើកឡើង នូវឧទាហរណ៍ យ៉ាងច្រើនហូរហែនោះទេ ។ ការពិភាក្សាមិនអាចទទួលជ័យជំនះ ដោយសារការលើកហេតុផលឱ្យបានច្រើន ជាគំនរធំនោះទេ ។ ហេតុការណ៍ច្រើន អាចប្រៀបបានទៅនឹងគំនរឥដ្ឋនៅក្នុងជញ្ជាំងអញ្ចឹង ។ ប្រសិនបើឥដ្ឋនោះផ្សារភ្ជាប់គ្នា ដោយគ្មានស៊ីម៉ង់ទេនោះ ឥដ្ឋនឹងគ្មានផលប្រយោជន៍ឡើយ យ៉ាងណាមិញការពិភាក្សាណាមួយក៏ដោយ មិនអាចយកជ័យជំនះតែម្នាក់ឯងបានទេ ដោយសារគ្រាន់តែថា ហេតុការណ៍ដែលក្រុមប្រឆាំងលើកនោះ មិនត្រឹមត្រូវ តែប៉ុណ្ណោះឡើយ ។ អំពើនេះគ្រាន់តែធ្វើឱ្យករណីរបស់គេចុះខ្សោយ បន្តិចតែប៉ុណ្ណោះ ហើយវាមិនខុសប្លែកពីការជញ្ជូនឥដ្ឋចេញពីជញ្ជាំងឡើយ ហើយឱ្យជញ្ជាំងនោះរំលំតែប៉ុណ្ណោះ ។ ដូច្នេះការវាយប្រហារ ចំណុចសំខាន់ៗរបស់ក្រុមម្ខាងទៀត ក៏មានន័យ ដូចការធ្វើឱ្យជញ្ជាំងរលំ ហើយដុំឥដ្ឋក៏គ្មានតម្លៃអ្វីទៀតឡើយ ។

- វិធីសាស្ត្រ : "រឿង ឬបញ្ហា" គឺអ្វីដែលត្រូវបានគេនិយាយលើកឡើង រីឯវិធីសាស្ត្រ គឺរបៀបដែលគេរៀបចំបង្កើតនូវ "បញ្ហា ឬរឿង"ឧទាហរណ៍ដូចជា :
- ក្រុមការងារ : វិធីសាស្ត្ររបស់ក្រុមល្អតែងតែមានការទាក់ទងទៅនឹងសាមគ្គីភាព និងការត្រិះរិះ រកហេតុផល ។ សាមគ្គីភាពលើកឡើងដោយសារសមាជិកទាំងអស់ ដែលនឹងស្គាល់និយមន័យ ស្គាល់អ្វីដែល អ្នកផ្សេងទៀតនិយាយ និងដឹងអ្វីដែលគោលការណ៍របស់ក្រុម ។ សមាជិកនៃក្រុមត្រូវពង្រឹង គោលការណ៍របស់ក្រុម និងមានអារម្មណ៍នឹងនរ មិនផ្លាស់ប្តូរជាមួយអ្វីដែលត្រូវបាននិយាយលើកឡើងរួចមកហើយ និងជាមួយអ្វីដែលនឹងត្រូវលើកឡើងដោយអ្នកផ្សេងទៀតនៃក្រុមរបស់គេ ។
- លក្ខណៈជាបុគ្គល : អ្នកនិយាយនីមួយៗត្រូវតែមានរៀបចំរចនាសម្ព័ន្ធ នៃសុន្ទរកថារបស់ខ្លួនឱ្យបានល្អ ។ ជំហានដំបូងគឺនិយាយត្រូវមានគំនិតច្បាស់លាស់ អំពីអំណះអំណាងរបស់ខ្លួន ហើយត្រូវមានឧទាហរណ៍

ច្បាស់លាស់ សម្រាប់យកមកបញ្ជាក់ និងគាំទ្រអំណះអំណាង។ នៅពេលពួកគេនិយាយ ពួកគេត្រូវបែងចែក ឱ្យច្បាស់រវាងអំណះអំណាងនីមួយៗ ហើយញ៉ាំងឱ្យអ្នកស្តាប់ដឹង ពេលដែលត្រូវគេផ្លាស់ប្តូរអារម្មណ៍ ពីអំណះអំណាងមួយទៅមួយទៀត។ សកម្មភាពនេះមានឈ្មោះថា "ចុះហត្ថលេខាប្រគល់តំណែង" (Sign posting) ហើយជាមធ្យោបាយ ដ៏សំខាន់សម្រាប់ការពិភាក្សា។

មធ្យោបាយគន្លឹះសម្រាប់សមាជិកចាំមិនភ្លេច គឺគេត្រូវស្គាល់យល់ដឹងឱ្យច្បាស់អំពីអ្វី ដែលពួកគេបាននិយាយ និងកំពុងនិយាយ ហើយអ្នកស្តាប់មិនធ្លាប់បានលឺពីមុនមក ហើយចង់ស្តាប់វា ដូច្នេះអ្នកនិយាយទាំងឡាយត្រូវតែមានការយល់ច្បាស់ក្នុងការយល់ដឹង។ សុន្ទរកថា ត្រូវរៀបចំ ស្របតាមពេលកំណត់ ហើយអ្នកវិនិច្ឆ័យ និងទទួលយកអ្នកនិយាយ ដែលបញ្ចប់សុន្ទរកថាស្របតាមពេល កំណត់មិនលើសមិនខ្វះ។

កំពុងតែរៀបរាប់គ្រាន់បំពេញនៅពេលវេលា។

**របៀបបែបបទ**

របៀបគឺសុន្ទរកថា ត្រូវថ្លែងឡើងដូចម្តេច ហើយរបៀបមានទិដ្ឋភាពរបស់វាប្លែកៗខ្លាំងណាស់ ដែលអ្នកនិយាយត្រូវដឹងរឿងនោះ។ របៀបបង្ហាញអំណះអំណាងមិនមានតែមួយនោះទេ។ ខាងក្រោមនេះ គឺជាការបង្ហាញឱ្យឃើញរបៀបខ្លះៗ :

- ស្លាកអក្សរ : ចូរកុំសរសេរសន្ទរកថានៅលើស្លាក ពីព្រោះការពិភាក្សាគឺជា និយាយឆ្លើយឆ្លងគ្នា ទៅវិញទៅមករវាងបុគ្គល និងបុគ្គល ឬក្រុមរវាងក្រុម ហើយនិងរវាងអ្នកស្តាប់ មិនមែនដោយអានសុន្ទរកថានោះទេ។ ស្លាកអក្សរត្រូវប្រើដើម្បីសំដែងតួតែប៉ុណ្ណោះ។ ស្លាកអក្សរសម្រាប់រំលឹកអ្នកដើរតួ ប្រសិនបើគេត្រូវការវា។
- ការសម្លឹងមើល ប្រសិនបើអ្នកនិយាយសម្លឹងមើលអ្នកស្តាប់ គេអាចទាញអារម្មណ៍អ្នកស្តាប់ឱ្យស្ថិតនៅជាមួយអ្នកនិយាយ។ ប្រសិនបើអ្នកនិយាយរវល់តែសម្លឹងមើលស្លាកអក្សរពេលគេធ្វើឱ្យអ្នកស្តាប់បាត់បង់អារម្មណ៍ ។
- សម្លេង : នឹងសម្លេងរបស់គេ អ្នកនិយាយអាចធ្វើអ្វីៗបានច្រើនយ៉ាងណាស់។ អ្នកនិយាយអាចតម្លើងសម្លេងដើម្បីសង្កត់អត្ថន័យ ឬទាញអារម្មណ៍អ្នកស្តាប់ ផ្តោតទៅលើអ្វីមួយ។ ជូនកាលនិយាយតិចៗធ្វើឱ្យអ្នកស្តាប់ខំផ្ទៀងត្រចៀកស្តាប់។
- រាងកាយ : រាងកាយ គឺជាសម្ភារដែលត្រូវប្រើប្រាស់។ ការប្រើដៃធ្វើកាយវិការត្រូវតែធ្វើ។ អ្នកនិយាយអាចងាកក្បាលចុះឡើងជុំវិញខ្លួន ដើម្បីទាញអារម្មណ៍អ្នកស្តាប់។
- ទម្លាប់ភ័យខ្លាច : ទម្លាប់ភ័យខ្លាចត្រូវតែចៀសវាង ទោះពេលកាលណាក៏ដោយ។ ការលេងជាមួយស្លាកអក្សរ ជំនួយការចងចាំ ការបោចសក់ក្បាល យកដៃគោះលើនាឡិកា ការយោលខ្លួន អាចនាំឱ្យបាត់ការផ្តោត

អារម្មណ៍របស់អ្នកស្តាប់។ អ្នកនិយាយត្រូវប្រើបុគ្គលភាពរបស់ខ្លួនទាំងអស់ ដើម្បីបញ្ចេញឥទ្ធិពល ហើយមិន ត្រូវបណ្តោយឱ្យសមត្ថភាពរបស់ខ្លួនថយចុះ ពិបាកអូសទាញសាធារណៈជននោះឡើយ។

- វោហារស័ព្ទ និងពាក្យពេចន៍ : រឿងនេះមិនមែន ជាលំហាត់វេយ្យាករណ៍ ឬលំហាត់សំនួនវោហារឡើយ។ អ្នកនិយាយត្រូវចៀសវាង ពាក្យដែលមិនត្រឹមត្រូវ ឬត្រឹមត្រូវហួសហេតុ។ គេមិនអាចទទួលពិន្ទុទេ ប្រសិនបើអ្នកស្តាប់មិនអាចយល់ ឬថាតាមមិនបាននោះ។ ម្យ៉ាងទៀតការប្រើប្រាស់សុន្ទរកថា ដែលគេសរសេរឱ្យនាំឱ្យមានការខុសឆ្គងចៀសមិនផុតឡើយ។ អ្នកនិយាយត្រូវរៀបចំគំនិតផ្ទាល់ខ្លួនសម្រាប់ចូលរួមការពិភាក្សា ដោយប្រើពាក្យងាយយល់។

## ការដាក់ពិន្ទុ

ការពិភាក្សាត្រូវវិនិច្ឆ័យ ដោយអាជ្ញាកណ្តាល អាជ្ញាកណ្តាលនីមួយៗ ដាក់ពិន្ទុឱ្យអ្នកនិយាយ ដោយផ្អែកទៅលើបទដ្ឋានច្បាស់លាស់។ ឧទាហរណ៍ដូចជា ពិន្ទុសរុបគឺ ១០០។ ពិន្ទុសរុបនេះ ត្រូវបែងចែកទៅតាមបទដ្ឋានដូចតទៅ : ៤០ សម្រាប់សាច់រឿងមួយ, ៤០សម្រាប់របៀប, ២០សម្រាប់វិធីសាស្ត្រ។ ប៉ុន្តែក្រុមមិនត្រូវខ្វល់អំពីពិន្ទុនោះទេ។ អ្វីដែលសំខាន់នោះគឺ ចូលរួមការពិភាក្សា ហើយទទួលបាននូវសមត្ថភាព ដែលអាចជួយយុវជននៅក្នុង ជីវភាពសិក្សាវិជ្ជាជីវៈ និងជីវភាពសង្គមរបស់គេ។

## គណៈកម្មការដឹកនាំ និងគ្រប់គ្រង

| | |
|---|---|
| ១_លោក ភុង ហនស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តួច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គូលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការរៀបរៀង និងចងក្រង

| | |
|---|---|
| ១_លោក ភុង ហនស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តួច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គូលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៦_លោក ឡង់ សុផាត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការបកប្រែ

| | | | |
|---|---|---|---|
| ១_លោកស្រី កង សុថាវី | ប្រធានការិយាល័យក្រោយអក្ខរកម្ម | ២_លោកស្រី តុប ប៊ុនថា | ប្រធានការិយាល័យអក្ខរកម្ម |
| ៣_លោក ញ៉ែម ភីណារ៉េត | អនុប្រធានការិយាល័យរដ្ឋបាល | ៤_លោក តេះ ដារី | អនុប្រធានការិ.ផែនការនិងគ្រប់គ្រងទិន្នន័យ |
| ៥_លោក ជិន និវត្តន៍ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_លោកស្រី ទី វត្តី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោក ភូ យន់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៨_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៩_កញ្ញា អ៊ុក ធារី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ១០_លោក គ្រួច លក្ខិណា | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ១១_លោកស្រី លី ខេង | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការផ្ទៀងផ្ទាត់

| | | | |
|---|---|---|---|
| ១_លោក សំ ចាន់ទិត | អនុប្រធានការិយាល័យអក្ខរកម្ម | ២_លោក រង់ សូវង្ស | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក ឈុំ ច័ន្ទមុនីរ៉េត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៤_លោកស្រី ជា សុផល | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក កែវ គង់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_កញ្ញា ម៉ៅ ផល្លី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការឌីហ្សាញ និងកុំព្យូទ័រ

| | |
|---|---|
| ១_លោក ឈិន វិត | ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ២_លោក ពេជ្រ និពន្ធ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៣_លោកស្រី ឈុំ សោភ័ណ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៤_លោកស្រី សួច ផាន់ណា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៥_លោកស្រី ទី រ៉ាដា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៦_កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |

# ✕ បញ្ឈប់ពលកម្មកុមារ

## Stop Child Labour

**Supporting Children's Rights through Education, the Arts and the Media (SCREAM)**


**សូមថ្លែងអំណរគុណ**

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មែនណាឌីរ ប៉ូល យ៉ូសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេង ឆវីរិទ្ធ** មន្ត្រីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់ (TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗ និងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្គ្រីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស លេខ 101 អយក ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦



នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : **(០២៣ ៧២៦ ៥៦៣ / ២១៩ ២៥៨**

**Email** : **nfe@camnet.com.kh**



ISBN- 9789995088217